BMI0058

សម្ភាសន៍ជាមួយឈ្មោះ សិត ញឹម ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ យោធានៅកងវរៈ២១ការពារព្រំដែន

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិគោកបុស្សី ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប

សព្វថ្ងៃរស់នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០០:៥៩:២៨

៣៨ទំព័រ

ឈុនលី ៖ ចឹងសូមឲ្យពូជួយប្រាប់ឈ្មោះ ពូឈ្មោះអីដែរ?

ញឹម ៖ សិត ញឹម ។

ឈុនលី ៖ អាយុប៉ុន្មាន?

ញឹម ៖ ៤៨ អូ! នែក។៥០ខុស ។

ឈុនលី ៖ ៥៧?

ញឹម ៖ ៥៣ ។

ឈុនលី ៖ អានេះនៅភូមិអីគេពូ?

ញឹម ៖ វាលរហាត់ ។

ឈុនលី ៖ វាលហាត?

ញឹម ៖ វាលរហាត់ ។

ឈុនលី ៖ ពូអ្នកស្រុកណាវិញ?

ញឹម ៖ ខ្ញុំនៅសៀមរាប ។

ឈុនលី ៖ ជាមួយមីងដែរ?

ញឹម ៖ ហ្នឹង ។

ឈុនលី ៖ ភូមិអីគេ ឃុំអីគេ?

ញឹម ៖ ភូមិគល់បុស្សី ។

ឈុនលី ៖ គល់បុស្សី?

ញ៉ឹម ៖ គោកៗបុស្ស៊ី ឃុំដានរុន ។

ឈុនលី ៖ ឃុំដែនរុន?

ញ៉ឹម ៖ ដាន ។

ឈុនលី ៖ ដានរុន

ញ៉ឹម ៖ ស្រុក......។ តែសព្វថ្ងៃនេះមិនដឹងដាក់អីទៀត ។

ឈុនលី ៖ ស្រុកសូទ្រនិគមន តែមិនដឹងភូមិគេដូរអត់ ។

ញ៉ឹម ៖ អត់ទេ ភូមិអត់ដូរទេ ដូរតែស្រុក ។

ឈុនលី ៖ ខ្ញុំចង់ដឹងថាដំណើរដំបូងមកហេតុអីបានពូមកដល់ទីនេះអីចឹង?

ញ៉ឹម ៖ ខ្មែរក្រហមចាប់ ។

ឈុនលី ៖ អានឹងពេលឆ្នាំណាវិញ?

ញ៉ឹម ៖ ពី៧៣ ។

ឈុនលី ៖ ឆ្នាំ១៩៧៣?

ញ៉ឹម ៖ បាទ!

ឈុនលី ៖ ពូអាចបញ្ជាក់រៀបរាប់បានទេ ថាមានរឿងអីកើតឡើងខ្លះ?

ញ៉ឹម ៖ អត់ទេ គ្រាន់គេកេណ្ឌឲ្យធ្វើទាហាននឹង ។

ឈុនលី ៖ ១៩៧៣នឹងពូនៅណា?

ញ៉ឹម ៖ ខ្ញុំនៅសៀមរាប ។

ឈុនលី ៖ នៅស្រុកកំណើតនឹង?

ញ៉ឹម ៖ ស្រុកកំណើតនៅគោកបុស្ស៊ី ។

ឈុនលី ៖ ចា៎! ប៉ុន្តែដូចថានៅក្នុងឆ្នាំ៧៣នឹង យើងនៅស្រុកភូមិយើងធម្មតា?

ញ៉ឹម ៖ អត់ទេ នៅធ្វើទាហាន កេណ្ឌចូលធ្វើទាហាន ។

ឈុនលី ៖ ចូលធ្វើទាហានឆ្នាំ៧៣ម៉ង?

ញ៉ឹម ៖ ៧៣ ។

ឈុនលី ៖ ធ្វើទាហាន ពេលនឹងហេតុអីបានពូធ្វើទាហាន?

ញ៉ឹម ៖ គេកេណ្ឌ ។

ឈុនលី ៖ ខាងណាគេកេណ្ឌ?

ញ៉ឹម ៖ ខ្មែរក្រហម ។

ឈុនលី ៖ អានឹងដើម្បីច្បាំងជាមួយខាង...? ចុះពេលនឹងពូចូលនៅក្នុង....?

ញឹម ៖ កងកាលនោះនៅវរៈ២១ ។

ឈុនលី ៖ ស្រុកអីគេ?

ញឹម ៖ នៅវរៈ២១នៅក្នុងខេត្តសៀមរាប ការពារ ។

ឈុនលី ៖ ស្រុកសូត្រនិគមននឹងដែរអត់?

ញឹម ៖ ស្រុកសូត្រនិគមនហ្នឹងដដែល ។

ឈុនលី ៖ ហើយកាលនឹងអ្នកណាគេអ្នកដឹកនាំទ័ពអីចឹង ខាងវរៈ?

ញឹម ៖ មេទ័ពដឹងអ្នកណាដឹកនាំភ្លេចបាត់ហើយ ។

ឈុនលី ៖ ភ្លេចបាត់?

ញឹម ៖ តាប្អូនៗ ។

ឈុនលី ៖ តាប្អូន ប្រធានកងវរៈ?

ញឹម ៖ ប្រធានកងវរៈ ដើរយកតាមផ្ទះកាលនោះ ។

ឈុនលី ៖ អូ! អន្កាល់ហ្នឹង ហើយចុះពូបានរៀនសូត្រអីត្រឹមថ្នាក់ទីប៉ុន្មាន?

ញឹម ៖ ពីដើមមិញថ្នាក់ទី៣ ។

ឈុនលី ៖ សាលាអីគេ?

ញឹម ៖ សាលាបឹងខ្យង ។

ឈុនលី ៖ បឋមហ្នឹងមែន?

ញឹម ៖ បាទ!បឋម ។

ឈុនលី ៖ ហើយចុះបន្ទាប់ពីធ្វើ.........?

ញឹម ៖ មានមកយើងចប់សម័យ៥ឆ្នាំ ។

ឈុនលី ៖ សម័យ៥ឆ្នាំ?

ញឹម ៖ បាទ! វាសម័យលន់ នល់វាមិនចប់៥ឆ្នាំ កាលនោះវាចូលសម័យ៣ឆ្នាំ ។

ឈុនលី ៖ ចុះខ្ទង់៧៤ ៧៥?

ញឹម ៖ ៧៤ ៧៥ វាធម្មតាដឹងថាច្បាំងធម្មតា ។

ឈុនលី ៖ ទៅច្បាំងរហូតចឹងទៅ?

ញឹម ៖ ច្បាំងរហូត ។

ឈុនលី ៖ ច្បាំងនឹងនៅកន្លែងណាទីតាំង?

ញឹម ៖ នៅមុខអង្គរៗវត្ត ។

ឈុនលី ៖ នៅមុខអង្គរវត្ត?

ញ៉ឹម ៖ បាទ!

ឈុនលី ៖ ហេតុអីបានច្បាំងនៅនឹងវិញ?

ញ៉ឹម ៖ ចុះបើគេកេណ្ឌ ។

ឈុនលី ៖ មុខអង្គរវត្ត អង្គរតូចហ្នឹង?

ញ៉ឹម ៖ បាទ! អង្គរ ។

ឈុនលី ៖ ចុះដល់ពេលចូលសម័យ៣ឆ្នាំ?

ញ៉ឹម ៖ សម័យ៣ឆ្នាំ ខ្ញុំទៅនៅព្រំដែន គេផ្លាស់ទៅព្រំដែនវិញ ។

ឈុនលី ៖ ឆ្នាំ៧៥ហ្នឹងម៉ង?

ញ៉ឹម ៖ បាទ! ៧៥ ថ្ងៃទីប៉ុន្មានភ្លេចបាត់គេឲ្យទៅនៅអន្លង់វែងនោះ ។

ឈុនលី ៖ កាលនឹងទៅគ្នាច្រើន ម៉ាកង?

ញ៉ឹម ៖ ទៅម៉ាវរៈ៥០០នាក់ ។

ឈុនលី ៖ អានឹងគេហៅម៉ាកងវរៈ?

ញ៉ឹម ៖ កងវរៈ ។

ឈុនលី ៖ ហើយម៉េចទៀតទៅពូ ធ្វើអីខ្លះ?

ញ៉ឹម ៖ មានធ្វើអីដឹងថា......របូត ។

ឈុនលី ៖ អ្នកណាគេអ្នកដឹកនាំទៅដល់ហ្នឹង?

ញ៉ឹម ៖ មេវរៈ ។

ឈុនលី ៖ ប្រធានវរៈហ្នឹង អ្នកណាគេ?

ញ៉ឹម ៖ តាអំៗគណៈតំបន់សៀមរាប គេបញ្ជូនទៅ ហើយតាអំគាត់ស្លាប់ហើយ ។

ឈុនលី ៖ តាអំគាត់ប្រធាន គណៈតំបន់?

ញ៉ឹម ៖ ភូមិភាគ មេ ។

ឈុនលី ៖ មេភូមិភាគនៅសៀមរាបហ្នឹង?

ញ៉ឹម ៖ សៀមរាប ។

ឈុនលី ៖ ហើយពេលទៅនឹងនៅដូចវាលវែងចឹង ទៅដល់នឹងគេមិនមានកងមួយទៀត?

ញ៉ឹម ៖ កងនេះភូមិភាគគេបញ្ជូនតាមវរៈៗដាក់អន្លង់វែង ម៉ាវរៈដាក់តាអុង ម៉ាវរៈគេដាក់កូនគ្រាល ។

ឈុនលី ៖ ចុះវរៈដែលពូទៅវាលវែង អានឹងគេហៅអីគេ?

ញ៉ឹម ៖ អន្លង់វែង ហ្នឹងវរៈ២១ដដែល ។

ឈុនលី ៖ ម៉េចចឹង ឈ្មោះដដែល គ្រាន់ថាផ្លាស់ទីតាំង?

ញឹម ៖ ហ្នឹងហើយផ្លាស់ទីតាំង កងវរៈដដែល តែផ្លាស់ទីតាំង ។

ឈុនលី ៖ ហើយកាលនឹងដូចច្បាំងគ្នាអីអត់ ឬមួយយ៉ាងម៉េច?

ញឹម ៖ អត់មានច្បាំងទេ ។

ឈុនលី ៖ ធ្វើអីទៅ?

ញឹម ៖ មានធ្វើអី គ្រាន់ការពារព្រំដែនតាមភ្នំដងរែកយើង ការពារ ។

ឈុនលី ៖ ការពារព្រំដែន?

ញឹម ៖ នៅព្រំដែន ។

ឈុនលី ៖ ហើយកាលនឹងអ្នកណាអ្នកដឹកនាំៗកងហ្នឹងឈ្មោះដដែល?

ញឹម ៖ កងពល ខ្ញុំភ្លេចឈ្មោះកងពលហើយ ប៉ុនចាំតែមេៗកងពលគឺ តាហ៊ាន ។

ឈុនលី ៖ គាត់ឈ្មោះអីទៅ?

ញឹម ៖ បាទ! ឈ្មោះ ហ៊ាន រងកងពលប៉ូល ។

ឈុនលី ៖ អាហ្នឹងមេកងពលម៉ង?

ញឹម ៖ មេកងពល ។

ឈុនលី ៖ មេកងពល ហើយនឹងមេវរៈនឹងខុសគ្នាម៉េច?

ញឹម ៖ ខុសគ្នា មានប្រធាន អនុប្រធាន សមាជិក ។ ម៉ាវរៈមានប្រធាន អនុប្រធាន សមាជិក ដល់សព្វថ្ងៃ បើខ្ញុំមិនស្គាល់ឈ្មោះគេសព្វថ្ងៃ ។

ឈុនលី ៖ កងពលធំជាង?

ញឹម ៖ ធំ កងពលយើងសព្វថ្ងៃសក្តិ៥ កងពល ហ៊ឺ!សក្តិ៥ចូលផ្កាយ១ ។

ឈុនលី ៖ ហើយនៅពេលទៅនៅនឹង ដូចការហូបចុកអី អត់អីទេ?

ញឹម ៖ អូ! ចាញ់ណាស់ គ្រុនចាញ់ ហើយមានសាប់ខ្វះ ។

ឈុនលី ៖ ចាញ់ ពេលទៅដល់ក្លាមចាញ់?

ញឹម ៖ ចាញ់ មានព្រៃទេរ ។

ឈុនលី ៖ នៅវាលវែង អឺ!អន្លង់វែង?

ញឹម ៖ អន្លង់វែងយើងសព្វថ្ងៃនឹង ។

ឈុនលី ៖ ហើយដល់ពេលចាញ់ចឹង គេមានពេទ្យមានអីត្រឹមត្រូវ?

ញឹម ៖ មាន ត្រឹមត្រូវថ្នាំសង្កូវអីមានគ្រប់គ្រាន់ ។

ឈុនលី ៖ តែរបបអីគ្រប់គ្រាន់ ហូបចុក?

ញ៉ឹម ៖ អត់ ក្នុងម៉ាថ្ងៃបានតែម៉ាកំប៉ុងកន្លះក្នុងម៉ាថ្ងៃ ។

ឈុនលី ៖ ម្នាក់?

ញ៉ឹម ៖ ម្នាក់ ។

ឈុនលី ៖ ហើយចឹងយើងបានអីហូបបន្ថែម?

ញ៉ឹម ៖ យើងអត់ ហូបទ្រាំទ្រ គេថាលុតដុំ ។

ឈុនលី ៖ ចឹងអ្នកដែលទៅនឹងសុទ្ធតែអ្នកលុតដុំ?

ញ៉ឹម ៖ លុតដុំ ចុះវាអតីត ចុះបើយើងនៅផ្ទះក៏នៅអត់បាន បើយើងខុសហរណ៍ថាយើងត្រូវកំនែន វាហើយ យើងនៅមិនបាន អ្នកណាចង់បែកម្ដាយបែកឪ បើគេកេណ្ឌយើងទៅហើយ ។

ឈុនលី ៖ ហើយចុះដូចពួទ័ពអីចឹង យើងមានធ្វើការអី មានធ្វើស្រែចំការអីដែរអត់?

ញ៉ឹម ៖ ធ្វើពីថ្ងៃនោះធ្វើ ។

ឈុនលី ៖ ចុះធ្វើទ័ព ហើយទៅដល់នោះយើងធ្វើស្រែ?

ញ៉ឹម ៖ ធ្វើស្រែធ្វើចំការផង ។

ឈុនលី ៖ កាលនោះពូមានគ្រួសារនៅ?

ញ៉ឹម ៖ នៅ ។

ឈុនលី ៖ ចុះបន្ទាប់ពីនឹងទៀត ដូចឆ្នាំ៧៥ ៧៦ ៧៧ ៧៨ មានរឿងរ៉ាវអីខ្លះ?

ញ៉ឹម ៖ អត់មានរឿងរ៉ាវអីទេ៧៦ ៧៨ អឺ!......៧៧ កាលនោះថាវាចាប់ក្បត់ ពិបាកនិយាយ ។

ឈុនលី ៖ ម៉េចខ្លះទៅ?

ញ៉ឹម ៖ វាពិបាកនិយាយថាអ្នកនិរតីមកចាប់អ្នកខត្ដរថាអ្នកខត្ដរក្បត់ វាមានរគេងរគាម វាចាប់បន្ដ ភ្នារបូត ។

ឈុនលី ៖ ខាងនិរតី?

ញ៉ឹម ៖ ចាប់ខត្ដរ ចាប់ភូមិភាគខត្ដរ ។

ឈុនលី ៖ ចោទថាក្បត់?

ញ៉ឹម ៖ ចោទថាក្បត់ ។

ឈុនលី ៖ ហើយកាលនឹងអ្នកណាទៅអ្នកមេធំខាងនិរតីនឹង....?

ញ៉ឹម ៖ សឿន ។

ឈុនលី ៖ គាត់មុខងាអ្វី?

ញ៉ឹម ៖ លោកសឿន ភូមិភាគ ។

ឈុនលី ៖ ភូមិភាគខាងនិរតី?

ញឹម ៖ ខាងនិរតី ភូមិភាគផង កងពលផង......។

ឈុនលី ៖ ហើយចឹងគាត់ធ្វើម៉េចទៅបើចោទថាក្បត់ចឹង ហើយចុះខាងខត្តរអ្នកណាគេទៅ?

ញឹម ៖ ខាងខត្តរមានទាហាន គេចាប់ពួកទាហាន ពួក ។

ឈុនលី ៖ ប៉ុន្តែអ្នកដឹកនាំខាងនឹង ខាងខត្តរនឹង?

ញឹម ៖ ខាងខត្តរចាប់អស់ហើយ គ្មាននៅទេ មេវរៈខ្ញុំតាសំ ។

ឈុនលី ៖ តាសំ?

ញឹម ៖ ហ្នឹងតាសំ គេចាប់អស់ហើយ នៅតែកូនៗ ។

ឈុនលី ៖ ប៉ុន្តែដូចមេធំជាងគេទៀត និយាយទៅស្បៀនហ្នឹង គាត់តួនាទីគាត់ធ្វើអី?

ញឹម ៖ ភូមិភាគផង កងពលផង ។

ឈុនលី ៖ ភូមិភាគផង កងពលផង?

ញឹម ៖ ហ្នឹងហើយ នៅភូមិភាគនិរតី ។

ឈុនលី ៖ ចុះអ្នកដែលនៅខាងភូមិភាគខត្តរវិញ?

ញឹម ៖ ខាងខត្តរតាប៉ូលៗទាហាន គេចាប់អស់ហើយ ។

ឈុនលី ៖ តាប៉ូល?

ញឹម ៖ គេចាប់អស់ហើយ និរតីគេចុះមកគេចាប់អ្នកខត្តរចេញ ។

ឈុនលី ៖ តែចាប់ហ្នឹង ចាប់យកទៅណា?

ញឹម ៖ ចាប់យកដាក់កាប៉ាល់ហោះទៅទួលស្លែង ចូលទួលស្លែង ។

ឈុនលី ៖ អូ! តាប៉ូល?

ញឹម ៖ តាប៉ូល ។

ឈុនលី ៖ តាប៉ូលប្រធានភូមិភាគ?

ញឹម ៖ ប្រធានកងពល ។

ឈុនលី ៖ ប្រធានកងពល២១ដដែល?

ញឹម ៖ បាទ!

ឈុនលី ៖ ចុះឈ្មោះតាអំ?

ញឹម ៖ តាសំៗ គេចាប់ហើយ ។

ឈុនលី ៖ តាសំហ្នឹងក្រែងគាត់?

ញឹម ៖ ប្រធានវរៈចាស់ ។

ឈុនលី ៖ ចុះគេដូរតាប៉ូលនឹងពេលណា?

ញឹម ៖ គេចាប់យកទៅទួលស្លែងហើយ ។

ឈុនលី ៖ ប្រធានកងពល?

ញឹម ៖ កងពល១ ប្រធានវរៈនឹងគេចាប់យកទៅអស់ ។

ឈុនលី ៖ ហើយចាប់យកទៅទួលស្លែងអាពេលនឹងឆ្នាំ៧៧?

ញឹម ៖ ៧៧ មិនដឹងថ្ងៃទីប៉ុន្មាន ដឹងឆ្នាំ៧៧ ។

ឈុនលី ៖ ម៉េចទៀតទៅដល់ពេលគេចាប់មេអស់ចឹង?

ញឹម ៖ យើងកូននៅធម្មតា យើងនៅតាមកន្លែងយើងធម្មតា គេចាប់មេយើងទៅអស់ហើយ បាន គេយកមេពីភូមិភាគនិរតីមកក្តាប់ម៉ាសារទៀត ។

ឈុនលី ៖ ចឹងពេលនឹងអ្នកណាគេអ្នកកាន់កាប់នឹង?

ញឹម ៖ តេវ ។

ឈុនលី ៖ ឈ្មោះតេវ?

ញឹម ៖ តេវ ប្រធានវរៈសេនាធំ ។

ឈុនលី ៖ ប្រធានវរៈសេនាធំ គ្រប់គ្រងនៅខាងអន្លង់វែង?

ញឹម ៖ ខាងអន្លង់វែង ។

ឈុនលី ៖ ហើយម៉េចទៀតពូ?

ញឹម ៖ មានអីទៀត គ្រប់គ្រងមកគឺវៀតណាមចូលស្រុកមកបណ្តោយចប់ត្រឹមហ្នឹង ងាប់អស់ហើយ អ្នកនេះងាប់អស់ ។

ឈុនលី ៖ ម៉េចបានពូដឹងថាគាត់ស្លាប់ហើយ?

ញឹម ៖ ស្លាប់នឹង អ្នកម៉ាខ្សែយើងហ្នឹងធ្វើបុណ្យ ។

ឈុនលី ៖ អឺ!ធ្វើបុណ្យពេលណា?

ញឹម ៖ ធ្វើបុណ្យនៅថ្ងៃទីប៉ុន្មានទេ គាត់ស្លាប់នៅស្រុកថៃ....។

ឈុនលី ៖ ស្លាប់នៅស្រុកថៃ?

ញឹម ៖ ស្លាប់ស្រុកថៃ ។

ឈុនលី ៖ អាហ្នឹងកាលឆ្នាំណា ប្រហែល យើងចូលមកនៅនេះនៅ?

ញឹម ៖ ទេ! ២០០០ប៉ុន្មានទេ ឆ្នាំនេះ២០១០ ២០០១ ២០០២ហ្នឹង ។

ឈុនលី ៖ ចុះខ្ទង់ឆ្នាំ ចុះមុនគាត់ស្លាប់នឹង គាត់រស់នៅណា?

ញឹម ៖ គាត់នៅសៀមរាប ។

ឈុនលី ៖ អូ! ចេញពីអន្លង់វែងមក គាត់នៅសៀមរាប?

ញឹម ៖ នៅសៀមរាប ផ្តាច់ខ្លួននៅសៀមរាប ។

ឈុនលី ៖ ចុះមុនផ្តាច់ខ្លួនគាត់នៅណាទៀត?

ញឹម ៖ មុនផ្តាច់ខ្លួននៅអន្លង់វែង ។

ឈុនលី ៖ ហើយចុះពូអាចរៀបរាប់ ពេលដែលចូលមកដល់ឆ្នាំ៧៩នេះ ហេតុអីបានពូរត់គេចមកនៅទីនេះ?

ញឹម ៖ ៧៩ វៀតណាមមកវាចេះតែខ្លាច ចេះតែគេចមក ។

ឈុនលី ៖ វៀតណាមចូលមកដល់ណាខាងអន្លង់វែង?

ញឹម ៖ អន្លង់វែងមើលមកដល់ ហ៊ើ!មកចូលដល់កន្លែងអន្លង់វែង សាលាស្រុកអន្លង់វែង ខ្ញុំគេចបែកគ្នាប្រុងប្រៀបអស់ហើយ ។

ឈុនលី ៖ អឺ! ចូលអន្លង់វែង អាហ្នឹងពេលហ្នឹងខែណា?

ញឹម ៖ ខែចែត្រ ខែ៤ ចូលខែ៤ ។

ឈុនលី ៖ នាំគ្នារត់ចេញមកខាង ចេញមកដំបូងមកនៅណា?

ញឹម ៖ ដំបូងនៅ......... ។

ឈុនលី ៖ ចុះពូថាវៀតណាមចូលដល់អន្លង់វែង ពេលហ្នឹងយើងមិនរត់ចេញមក?

ញឹម ៖ ពេលចេញវិញយើងមកតាមព្រំដែន យើងគេចទៅនៅតាមខ្នងភ្នំដងរែក ។

ឈុនលី ៖ ហើយយើងនៅខ្នងភ្នំដងរែកម៉ង?

ញឹម ៖ ហ្នឹងហើយ នៅឡាក់... ។

ឈុនលី ៖ អានឹងគេហៅតំបន់អី?

ញឹម ៖ តំបន់.........មិនដឹងដែរ.... ។

ឈុនលី ៖ ពេលនឹងគ្នាច្រើនទេ?

ញឹម ៖ ច្រើនដែរ រត់ម៉ាប្រទេសកម្ពុជាហ្នឹងរត់មកខាងលិចនេះផង ទៅខាងជើងផង វាទៅ២ប៉ែកនិយាយរួមអតីតទាំងអស់មកនេះទាំងអស់ ។ ខ្លះណាគេសារភាពទាំងអស់ទៅ ខ្លះណាគេមកនេះមក ។

ឈុនលី ៖ សារភាពទៅ យើងចូលជាមួយគេ?

ញឹម ៖ ហ្នឹងហើយ ជាមួយរាជរដ្ឋាភិបាល ។

ឈុនលី ៖ ចុះដូចពូកាលហ្នឹងម៉េចបានពូអត់ចូលជាមួយគេ?

ញឹម ៖ ចុះយើងមានដឹងណា ពាក្យឃោសនារបស់គេ ។

ឈុនលី ៖ មកតាមគេរហូត?

ញឹម  :   មកតាមគេ យើងបែកពីគេខ្លាចគេសម្លាប់ចោល ។

ឈុនលី : ព្រោះយើងធ្លាប់?

ញឹម  :   ហើយចឹងយើងចេះដើរតាមគេ យើងកូនគេ ។

ឈុនលី : ហើយចុះពេលមកនៅតំបន់នេះដំបូងចឹង ពូមានដឹងទេថាអានឹងគេហៅតំបន់អីគេ?

ញឹម  :   អត់ដឹងទេ តំបន់អីគេ ។

ឈុនលី : តែមើលទៅស្ថានភាពម៉េចដែរ ខ្ញុំឮថាមានព្រៃ?

ញឹម  :   ព្រៃៗច្រើនណាស់ ព្រៃធំ ព្រៃខ្លា ព្រៃដំរី ។

ឈុនលី : តែពូមកដល់ហ្នឹងឃើញ ដែលធ្លាប់ឃើញសត្វព្រៃ?

ញឹម  :   ឃើញតើ ។

ឈុនលី : ហើយធ្វើម៉េចទៅ បើសុទ្ធតែព្រៃចឹង?

ញឹម  :   វាសុទ្ធតែព្រៃ វាចេះតែនៅតាមព្រៃ តាមកងគេឲ្យនៅម៉ាកងនៅនេះម៉ាកងនៅនោះ ហើយគេរៀបជាភូមិ ។

ឈុនលី : តាមកងវរៈហ្នឹង?

ញឹម  :   ទេ! ត្រឹមភូមិ ។

ឈុនលី : កងរបៀបម៉េច?

ញឹម  :   កងគេឃើងមេ យើងកងទាហាន យើងនៅម៉ាកន្លែងយើង យើងមកទម្លាប់តាមគ្រួសារចេះទៅគេដាក់តាមភូមិៗនេះភូមិនេះភូមិនោះ ។

ឈុនលី : ចឹងមានជួបអ្នកដែលមកពីខាងក្នុងមកទេ?

ញឹម  :   អត់ទេ ។

ឈុនលី : ហើយមានដឹងទេថាតំបន់ហ្នឹង មុនដំបូងស្ថិតនៅក្នុងស្រុកអីគេ ពីដើម?

ញឹម  :   ស្រុកម៉ាឡៃ ។

ឈុនលី : គេបង្កើតស្រុកហើយ គេបង្កើតស្រុកម៉ាឡៃហើយ?

ញឹម  :   បង្កើតស្រុកម៉ាឡៃ ។

ឈុនលី : ៧៩ហ្នឹង?

ញឹម  :   ៧៩ ក៏ស្រុកម៉ាឡៃដែរ ។

ឈុនលី : .....ពូនៅដំបូងទីតាំងនៅណា ពេលចូលមកដល់ស្រុកហ្នឹងមុនគេ?

ញឹម  :   ទីតាំងនៅខ្លាងាប់ ។

ឈុនលី : ហើយចឹងគេមិនបង្កើតកង ចឹងមានពេទ្យមានអី?

ញ៉ឹម ៖ មាន ។

ឈុនលី ៖ ហើយចុះស្បៀងអីគ្រប់គ្រាន់?

ញ៉ឹម ៖ ស្បៀងអត់ខ្វះ មានខ្វះ ឆ្អែតខ្វះមិនឆ្អែតខ្វះ យើងវៃចាញ់គេ យើងរត់នោះ ។

ឈុនលី ៖ ដាច់ស្បៀង?

ញ៉ឹម ៖ យើងរត់ ចាញ់ឃោសនារបស់គេ គេថាមេនៅនឹងឯងឲ្យទៅនៅនោះ ទោះហ៊ានបែកមិនបែក គេសម្លាប់ចោល ចេះតាមហ្នឹង ។

ឈុនលី ៖ ចុះពូបើគិតទៅមកដល់នេះចឹង ដំបូងចឹងខ្ញុំពូថាពិបាក ប្រជាជនថាពិបាក?

ញ៉ឹម ៖ ពិបាកអារឿងគ្រូនចាញ់ ។

ឈុនលី ៖ ហើយអីទៀតទៅ?

ញ៉ឹម ៖ មានតែរឿងគ្រូនចាញ់ធ្ងន់ ។

ឈុនលី ៖ ចាញ់ខ្លាំង?

ញ៉ឹម ៖ ចាញ់ ហូបអីតែមិនស្រួល ។

ឈុនលី ៖ ហូបអីដែលអាចចាញ់?

ញ៉ឹម ៖ អត់ទៀតទេ ។

ឈុនលី ៖ ទឹក?

ញ៉ឹម ៖ បើយើងទឹកយើងដាំធម្មតា បើផ្លែឈើយើងហូបវាមិនទៀងដែរ ជួនកាលយើងហូបផ្លែនេះ វាអត់ឆាប់ ហូបផ្លែឈើនោះឆាប់ ។

ឈុនលី ៖ អាហ្នឹងហេតុអីបានចឹង?

ញ៉ឹម ៖ មិនដឹងម៉េចព្រៃច្រើនកាលនោះយើងមិនដែលមានថ្ងៃ មើលឃើញព្រៃរបូត ។

ឈុនលី ៖ គ្រុជាក់មែង?

ញ៉ឹម ៖ គ្រុជាក់ ។

ឈុនលី ៖ រផា?

ញ៉ឹម ៖ គ្រុជាក់រផា ហើយមូសវាច្រើនទៀត ។

ឈុនលី ៖ អត់ដែលឃើញថ្ងៃ?

ញ៉ឹម ៖ ឃើញតែវាឃើញ...ព្រៃខ្លាព្រៃដំរី ។

ឈុនលី ៖ ហើយបើគិតទៅពេលនៅនឹងភ្នាម មានអ្នកស្លាប់ច្រើន?

ញ៉ឹម ៖ ស្លាប់តាមកងម៉ាថ្ងៃ១ ម៉ាខែ១ ។

ឈុនលី ៖ ម៉ាថ្ងៃ១ អានឹងចូលដំបូង?

ញឹម ៈ ចូលដំបូង យូរទៅវាថយតិចៗ ។

ឈុនលី ៈ ចូលដល់ឆ្នាំប៉ុន្មានហើយ?

ញឹម ៈ ឆ្នាំ……ឆ្នាំ៨០ ។

ឈុនលី ៈ ចូលដល់៨០ហើយ?

ញឹម ៈ បាទ!

ឈុនលី ៈ ចុះពូមានគ្រួសារនៅឆ្នាំណា?

ញឹម ៈ ប៉ុន្មាន៨៥ ៨៦ ចាំវាមិនបាននៅនោះ ។

ឈុនលី ៈ ពេលនឹងពូនៅណា?

ញឹម ៈ មានគ្រួសារនៅអន្លង់វែង ។

ឈុនលី ៈ អឺ! ម៉េចនៅអន្លង់វែង ឆ្នាំ៨៦?

ញឹម ៈ ….៨៦ ។

ឈុនលី ៈ ចេញពីអន្លង់វែងឆ្នាំ៨៦?

ញឹម ៈ ចេញពីអន្លង់៨៧ ។

ឈុនលី ៈ អឺ! ចុះអាពេលពូថាចាញ់៨០?

ញឹម ៈ វាចាញ់មកមុនគេមកនៅមុន យើងមកក្រោយក៏ចាញ់ដូចគ្នាដែរ ។

ឈុនលី ៈ អូ! ចឹងពូមកនេះនឹងឆ្នាំ៨៦ទេ?

ញឹម ៈ ៨៦ គេដោះដូរគ្នា ។

ឈុនលី ៈ ខ្ញុំអត់យល់ពូម៉េចទៅ?

ញឹម ៈ គេដោះដូរខទាហរណ៍ថាកងនេះគេនៅនោះ យកកងនោះមកដាក់នេះគេដូរគ្នា ។

ឈុនលី ៈ តែពូថារត់មកនេះ ឆ្នាំ៧៩?

ញឹម ៈ ៧៩យើងរត់មកនេះយើងកាច់ទៅនោះវិញ ទៅបណ្តោយតាមភ្នំឆ័ត្រវិញ ។

ឈុនលី ៈ ចឹងបានន័យថាពូមកដល់តំបន់នឹងបានត្រឡប់ទៅវិញ?

ញឹម ៈ ហ្នឹងហើយ ត្រឡប់ទៅផ្ទះវិញ ។

ឈុនលី ៈ ត្រឡប់ចឹងដើម្បីអី?

ញឹម ៈ គេដូរ ។

ឈុនលី ៈ តែអ្នកគ្រប់គ្រងយើងដដែល?

ញឹម ៈ មេគេនាំតាមកងតាមវរៈគេ ។

ឈុនលី ៈ ចុះតែក្រែងថាវៀតណាមចូលមកដល់កន្លែងអន្លង់វែងហើយ?

ញឹម ៖ ចូលអន្ទង់វែង ខ្ញុំនៅលើភ្នំ ។

ឈុនលី ៖ តែយើងនៅក្នុងកងដដែល?

ញឹម ៖ នៅកងដដែល ហើយដងវែកនៅក្រោមទៅ នៅលើហ្នឹងទៅ ។

ឈុនលី ៖ ហើយចុះមីងគាត់ធ្វើអី?

ញឹម ៖ មីងនេះគាត់ខាងដឹកជញ្ជូន ។

ឈុនលី ៖ ជញ្ជូនៗអីគេ?

ញឹម ៖ ជញ្ជូនគ្រាប់ ។

ឈុនលី ៖ ......?

ញឹម ៖ ដឹកស្បៀង ។

ឈុនលី ៖ អាហ្នឹងដឹកពីណាទៅណា?

ញឹម ៖ ពីខ្នងភ្នំដងវែកមកដីរាប ។

ឈុនលី ៖ ដើរឆ្ងាយទេ?

ញឹម ៖ ទេ! ដេកផ្លូវ៣យប់ ។

ឈុនលី ៖ អាហ្នឹងទាល់តែស្រីៗបានគេឲ្យកងដឹកជញ្ជូន?

ញឹម ៖ ស្រីផង ទ័ពផង និយាយរួមគឺនារី ហើយនឹងយុទ្ធជនៗគឺទ័ព ហើយនារីអ្នកទូល ទ័ពអ្នកបើកផ្លូវ នារីអ្នកជញ្ជូនទៅ ។

ឈុនលី ៖ ហើយឃើញទៅក៏រៀប ហើយកាលហ្នឹងគេរៀបការប៉ុន្មានគូទៅ?

ញឹម ៖ ប៉ុន្មានទេ កាលការខ្ញុំ ទេ!ការតែឯង ។

ឈុនលី ៖ អានឹងគេស្នើទ័ព?

ញឹម ៖ ស្នើយើងត្រូវគ្នាគេឲ្យ យើងមិនត្រូវគ្នា ។

ឈុនលី ៖ គិតទៅ៨០ប៉ុន្មានពេលការនឹង?

ញឹម ៖ ៨០ប៉ុន្មានទេ ភ្លេចហើយចាំអត់បានទេ ។

ឈុនលី ៖ ចុះដល់ពេលពូចេញមកនេះម្ដងទៀត?

ញឹម ៖ មកម្ដងចេះទៅវិញៗទៅមកគេដូរចុះដូរឡើង ។

ឈុនលី ៖ ចុះឆ្នាំណាដែលយើងមកនេះជាប់រហូត?

ញឹម ៖ ជាប់ពី មកនៅនេះជាប់កាលអ៊ុន គាត់ៗចូល ។

ឈុនលី ៖ ចុះពូមានបានជម្លៀសទៅថៃទេ?

ញឹម ៖ អត់ទេ អត់ដែលចូលទេ អត់ដែលបានមាតុភូមិនិវត្តន៍នឹងគេ ។

ឈុនលី ៖ ហើយចុះកាលនឹងទៅមកៗ ប៉ុន្តែទីតាំងនឹងនៅម្តុំខាងរាប់ហ្នឹងទេ?

ញឹម ៖ បាទ! ទាហានកន្លែងទាហាន ។

ឈុនលី ៖ ចុះតំបន់នេះមានខាងខ្មែរក្រហម ហើយខាងណាទៀត?

ញឹម ៖ ខាងខ្មែរក្រហមហើយនឹងវៀតណាម ។

ឈុនលី ៖ ចុះវៀតណាមចូលដល់ណាវិញ?

ញឹម ៖ វៀតណាមចូលមកដល់នេះម្តង វៀតណាមដកទៅវិញ ខ្មែរក្រហមចូល ។

ឈុនលី ៖ ទីតាំងហ្នឹងម៉ង?

ញឹម ៖ ហ្នឹងវៀតណាមនៅតាមហ្នឹង ។

ឈុនលី ៖ ហើយចឹង ដូចពួចេញចូលអីចឹង មានដាក់មីនដាក់អីដែរ?

ញឹម ៖ ដាក់ ពីសម័យនឹងដាក់ ។

ឈុនលី ៖ ខាងណាដាក់?

ញឹម ៖ ខ្មែរក្រហមក៏ដាក់ វៀតណាមក៏ដាក់ ។

ឈុនលី ៖ ខាងអន្ទង់វែងមានអត់?

ញឹម ៖ ដូចតែគ្នា ចុះមកចឹងមកដាក់ក៏ដាក់ទៅ អ្នកណាមកក្រោយក៏ដាក់ៗទៅដាក់មករបូត ។

ឈុនលី ៖ ចុះខាងអន្ទង់វែងចឹង អ្នកណាអ្នកគ្រប់គ្រងធំម៉ាតំបន់?

ញឹម ៖ តាម៉ុក ។

ឈុនលី ៖ អូ! តាម៉ុកអ្នកគ្រប់គ្រង ។ ចឹងពួចូលមកដល់នេះឆ្នាំ៩៣?

ញឹម ៖ ៩៣ ។

ឈុនលី ៖ ពេលបោះឆ្នោត ចុះឆ្នាំ៩០អីនៅតែចេញចូលចឹង?

ញឹម ៖ ចេញចូលដូរគ្នាតាមព្រំដែន ។

ឈុនលី ៖ តែហូបចុកអីគ្រប់ទេពេលនឹង?

ញឹម ៖ គ្រប់តើ ដល់៨០ ៨១ ចាប់ពី៨១ទៅគ្រប់ ហូបរៀងគ្រាន់ ។

ឈុនលី ៖ ៨១នៅណានៅនេះ?

ញឹម ៖ នៅនេះ ទៅមកៗដូរគ្នាទៅមក ។

ឈុនលី ៖ រយៈពេលប៉ុន្មានដែលយើងទៅមក ដូចថាយើងនៅនេះបានប៉ុន្មាន បានយើងទៅវិញ?

ញឹម ៖ ម៉ាខែ ២ខែបានទៅវិញ ដើរតាមស្របព្រំដែន ។

ឈុនលី ៖ ចឹងអ្នកខាងនោះគេមកនេះ យើងទៅវិញ?

ញឹម ៖ បាទ! ទៅវិញទៅមក ។

ឈុនលី ៖ ហេតុអីបានចឹងវិញ?

ញឹម ៖ ដោះដូរគ្នា កាលណាយើងនៅនេះយូរទៅ គេដូរទៅនោះ វាមិនដឹងដែរផែនការនៅលើគេស្រេចមេយើងបញ្ជា ។

ឈុនលី ៖ ចុះពេលពូមកដល់តំបន់នេះ ពូមានដឹងទេថាអ្នកណាគេអ្នកគ្រប់គ្រងតំបន់នឹង?

ញឹម ៖ នៅនេះខ្ញុំស្គាល់តែបងភាពមួយ ។

ឈុនលី ៖ គាត់ប្រធានតំបន់?

ញឹម ៖ កងពល ។

ឈុនលី ៖ មេកងពល ។ កងពលប៉ុន្មាន?

ញឹម ៖ កងពលភ្លេចបាត់ កងពលចាំអត់បានកងពលៗ បើស្គាល់មុខភាព ។

ឈុនលី ៖ កាលនឹងគាត់ក្មេងដែរ?

ញឹម ៖ ភាព ។

ឈុនលី ៖ ចាំ! អាយុប៉ុន្មាន?

ញឹម ៖ អឺ! សព្វថ្ងៃ៦០ដឹង ចូល៦០ជាងហើយ ។

ឈុនលី ៖ ចឹងបានន័យថាពេលនឹងគាត់៤០ជាង?

ញឹម ៖ អាច៥០ជាង ៥០ឬក៏៤០ ។

ឈុនលី ៖ ចុះពេលយើងចូលមកដល់ស្រុកនេះ ដូចឆ្នាំ៩៣អីចឹង ដូចស្ថានភាពនៅនេះម៉េចដែរមានគេរស់នៅច្រើន?

ញឹម ៖ អត់មានៗ ។

ឈុនលី ៖ ម៉េចបានអត់មានចឹង?

ញឹម ៖ ស្ងាត់ ទ្រឹងៗមានខ្លាមានដំរី ។

ឈុនលី ៖ សុទ្ធតែព្រៃទៀតហើយ?

ញឹម ៖ សុទ្ធតែព្រៃ ។

ឈុនលី ៖ ចុះយើងធ្លាប់ចេញចូលនៅតែមានព្រៃទៀត?

ញឹម ៖ នៅមានព្រៃ យើងមានបង្កើតមួយចេះតែពង្រាយតាមកង ។

ឈុនលី ៖ កាប់ព្រៃកាប់អី?

ញឹម ៖ កាប់ព្រៃធ្វើផ្ទះសម្បែងនៅ ។

ឈុនលី ៖ ហើយនៅមីនអត់?

ញឹម ៖ ដោះៗខ្លួនឯង ដោះចាប់ដីរៀងខ្លួន ។

ឈុនលី ៖ ពូចាប់ដីមុនដំបូងនៅណា?

ញ៉ឹម ៖ ខ្ញុំពីដើមមិញនៅជិតផ្សារ ដល់គេបិទផ្លូវជិត យើងនៅក្រោយគេ ហើយគេអ្នកមានគេនៅមុខ ទៅគេបិទផ្លូវ ។

ឈុនលី ៖ មានអ្នកណាគេមក?

ញ៉ឹម ៖ នោះគេនៅខាងភ្នំឆត្រ ។

ឈុនលី ៖ ពេលណាគេមក?

ញ៉ឹម ៖ ៨០ប៉ុន្មានទេ ៨៩ទេដឹង ចាំអត់បាន គេមានទៅគេទិញដីនៅមុខទៅ ។

ឈុនលី ៖ ពួកគាត់ទ័ពដែរអត់?

ញ៉ឹម ៖ ទ័ពគេ ។

ឈុនលី ៖ ដូចថាគេចេញមកមុន?

ញ៉ឹម ៖ គេខាងទូតណា គេខាងទាក់ទងខាងថៃចេញចូល ។

ឈុនលី ៖ ឥឡូវនឹងគាត់នៅនឹងរហូត?

ញ៉ឹម ៖ .... ។

ឈុនលី ៖ អ្នកណាគេ?

ញ៉ឹម ៖ ភីន ទាក់ទងថៃ ស្លាប់អស់ហើយ ។

ឈុនលី ៖ ហើយដល់ពេល ចុះពូមកនៅនេះពេលណា?

ញ៉ឹម ៖ ខ្ញុំទិញដី.......... អត់ចាំខុសគ្នា.......(ខ្យល់) .... ។

ឈុនលី ៖ ៩៣ ៩៤ មាន...?

ញ៉ឹម ៖ នៅតិចណាស់ ។

ឈុនលី ៖ គេទៅណាអស់?

ញ៉ឹម ៖ គេនៅតែជុំគ្នា គេនៅម្តុំៗ ។

ឈុនលី ៖ ម្តុំហ្នឹងភាគច្រើនគេនៅណា?

ញ៉ឹម ៖ នៅផ្សារយើង ។

ឈុនលី ៖ ម្តុំផ្សារហ្នឹង?

ញ៉ឹម ៖ បាទ!

ឈុនលី ៖ ចឹងអ្នកដែលនៅនឹង សុទ្ធតែអ្នកជម្លៀសទៅណា ឬមួយក៏នៅនឹងរហូត?

ញ៉ឹម ៖ នៅៗតែហ្នឹងរហូត ។

ឈុនលី ៖ មែនអ្នកដែល ខ្ញុំឮថាដូចជាមានខាងជម្លៀសទៅថៃអី...?

ញឹម ៖ អូ! កាលនឹងគេដកៗទៅនៅថៃ នៅ៨៥ យួនបុកនៅតាមនេះហ្នឹងនៅ៨៥ ដល់វៀតណាម ដកទៅវិញ គេមកវិញ ។

ឈុនលី ៖ ចុះគេមកវិញហ្នឹងខ្ទង់ឆ្នាំណាពូដឹង?

ញឹម ៖ អត់ដឹង ។

ឈុនលី ៖ ប៉ុន្តែពេលពូមកហ្នឹង គេអត់ទាន់មកវិញទេ?

ញឹម ៖ មកហើយ ។

ឈុនលី ៖ មកហើយ ច្រើនទេកាលនឹងពូ?

ញឹម ៖ ច្រើន ។

ឈុនលី ៖ ចឹងបានន័យថាកាប់ព្រៃនៅម្តុំៗគ្នាឯង?

ញឹម ៖ នៅម្តុំៗគ្នាឯង ខ្លាចកាលនឹង ។ យើងកាលនោះគ្មាននេះ មានតែរត់ ។

ឈុនលី ៖ ចុះតំបន់នឹងចាប់ផ្តើមអស់ព្រៃអស់អីពេលណា?

ញឹម ៖ អស់ព្រៃបោះឆ្នោតរួច អស់ព្រៃច្រើន ។

ឈុនលី ៖ ខាងណា?

ញឹម ៖ អូ!នែកបោះឆ្នោត២០០០ អឺ!៩៨ ៩៩ ។

ឈុនលី ៖ ៩៣ បោះឆ្នោត៩៣?

ញឹម ៖ ៩៣ចាប់ពី៩៣នេះទៅបណ្តើរៗ ។

ឈុនលី ៖ ចុះយើងចូលផ្តាច់ខ្លួននេះនៅឆ្នាំណា?

ញឹម ៖ ៩៩ ៩៨ទេ ។

ឈុនលី ៖ ៩៦ ៩៧?

ញឹម ៖ ៩៦ ។

ឈុនលី ៖ ៩៦?

ញឹម ៖ ៩៦ចាំអត់បានទេ ផ្តាច់ខ្លួន.... ។

ឈុនលី ៖ ៩៦ ៩៧ ។ ចុះពេលពូមកនៅនេះដំបូងចឹង ដូចថាជីវភាពរស់នៅការរស់ ហើយរបៀបថា ការរស់នៅរបស់យើងម៉េចដែរ?

ញឹម ៖ យើងមានអីយើងធម្មតា ។

ឈុនលី ៖ យើងធ្វើអី?

ញឹម ៖ ធ្វើកាប់ចំការ ធ្វើចំការធ្វើអី ។

ឈុនលី ៖ ចឹងពេលមកដល់នេះយើងគេចែកដីឲ្យ?

ញឹម ៖ អត់ទេ ចាប់យករៀងខ្លួន អ្នកណាចាប់បានច្រើនៗ អ្នកណាចាប់បានតិចក៏តិច ។

ឈុនលី ៖ ហើយពូចាប់បានច្រើន កាលនឹងចាប់នៅម្ដុំ....?

ញឹម ៖ អត់ទេ អត់បានច្រើន ទិញគេ ។

ឈុនលី ៖ ហើយចឹងយើងដាំអីម៉េចទៅ?

ញឹម ៖ ដាំស្លឹកគ្រៃហូបតិច ។

ឈុនលី ៖ ចុះអង្ករ?

ញឹម ៖ អង្ករបើក ។

ឈុនលី ៖ បើកគ្រប់គ្រាន់ទេ?

ញឹម ៖ គ្រប់ ម៉ាខែស្មើម្នាក់ម៉ាបោត ។

ឈុនលី ៖ ម៉ាខែម៉ាបោត ហើយកាលនឹងពូមានគ្នា២នាក់?

ញឹម ៖ គ្នា២នាក់ ។

ឈុនលី ៖ អត់ទាន់មានកូន?

ញឹម ៖ អត់ទាន់មានកូន ហ៊ើ!មានហើយ មានសកូនតូចមួយ ។

ឈុនលី ៖ កូនហ្នឹងកើតនៅណា?

ញឹម ៖ កើតនៅម៉ាឡៃ អឺ!កើតនៅភ្នំឆ័ត្រ អូ!នែកអន្លង់វែង ។

ឈុនលី ៖ ភ្នំឆ័ត្រនឹង អានឹងនៅស្រុកអីគេ?

ញឹម ៖ ភ្នំឆ័ត្រថ្មពួក ។

ឈុនលី ៖ សៀមរាប?

ញឹម ៖ ទេ! ថ្មពួកយើងបន្ទាយមានជ័យៗ....។

ឈុនលី ៖ មង្គលបូរី?

ញឹម ៖ ស្រុកស្អី កាលនោះដឹងតែខ្មែរក្រហមនៅនោះមិនដឹងស្រុកទេ ដឹងថាស៊ីសាផុនខាងជើង ស៊ីសាផុនខាងត្បូង ហើយស្រុកអត់ទាន់ដឹង ។

ឈុនលី ៖ ហើយចឹងដូចការរស់នៅអីចឹង មានអីខ្វះខាតទេ?

ញឹម ៖ អត់មាន ។

ឈុនលី ៖ ហើយមានការលំបាកទេ ពេលហ្នឹង?

ញឹម ៖ វាលំបាកៗ រឿងគ្រុនចាញ់ ។

ឈុនលី ៖ ៩០ ដាងមានគ្រុនចាញ់ទៀត?

ញឹម ៖ មាន ។

ឈុនលី ៖ ហើយដល់ពេលយើងគ្រូនឈឺចឹងយើងទៅរកអ្នកណា?

ញឹម ៖ ពេទ្យ ។

ឈុនលី ៖ ពេទ្យខ្មែរក្រហម?

ញឹម ៖ ពេទ្យរដ្ឋ ពេទ្យខ្មែរក្រហម ។

ឈុនលី ៖ ពេលនឹងមានអ្នកចំណូលថ្មីចូលមកនៅ?

ញឹម ៖ មាន ។

ឈុនលី ៖ ចាប់ផ្តើមមានបណ្តើរៗ?

ញឹម ៖ មានៗ ផ្លាច់ខ្លួនរួចបានច្រើន..... ។

ឈុនលី ៖ ចុះឆ្នាំ៩៣ហ្នឹងមានបាញ់គ្នាអីទៀតអត់?

ញឹម ៖ ៩៣អត់ ហ៎! ៩៣នៅមិនទាន់ផ្តាច់ខ្លួន ៩៣ ។

ឈុនលី ៖ ចាំ! អត់ទាន់ ។

ញឹម ៖ នៅវៃគ្នានៅខាងផាប់ ។

ឈុនលី ៖ នៅណាខាងផាប់?

ញឹម ៖ ខាងផាប់យើងផ្លូវចូលមក អាបន្ទាយទី១ ហៅបន្ទាយទី១... ។

ឈុនលី ៖ វៃហ្នឹងជាមួយពួកណា?

ញឹម ៖ ពួកខ្មែរនិងខ្មែរ កាលនឹងវៀតណាមដកអស់ហើយ ទប់មុខបានម៉ាឆ្នាំ បាន ។

ឈុនលី ៖ ហេតុអីបានច្បាំងគ្នាម៉េច ពេលនឹង?

ញឹម ៖ អត់ទេ គេនយោបាយរបស់គេអត់ដឹង ហើយយើងមួយខៀវ មួយស ។ យើងហៅអាខៀវ យើងប្រុងអាខៀវ គេខាងអាសគេប្រុងអាស គេអ្នកបញ្ជាគេបញ្ជា យើងធ្វើម៉េចយើងក្រោមអាណានិគមន៍របស់គេ ឲ្យទៅផាប់មានផាប់ ឲ្យទៅរស់យើងរស់ ។

ឈុនលី ៖ ហើយចឹងពួដូចធ្វើទ័ពចឹង យើងទៅច្បាំងរហូត?

ញឹម ៖ ទៅរហូត ។

ឈុនលី ៖ ចុះប្រពន្ធ?

ញឹម ៖ ប្រពន្ធកូនមានវេណ ។

ឈុនលី ៖ ម៉េចទៅ?

ញឹម ៖ ម៉ាខែអីដូរគ្នាម្តង ។

ឈុនលី ៖ ដូរជាមួយអ្នកណាគេ?

ញឹម ៖ ដូរឧទាហរណ៍ថាម៉ាក្រុមចេះម៉ាកងចេះ ទៅម៉ាកងៗឡើងម៉ាកងចុះ ដូរគ្នា ។

ឈុនលី ៖ ហើយទៅម្ដងរយៈពេលប៉ុន្មាន?

ញឹម ៖ ម៉ាខែ ។

ឈុនលី ៖ ចឹងដល់ពេលពេលពូទៅច្បាំងចឹង ប្រពន្ធនៅផ្ទះម៉ាខែ?

ញឹម ៖ ម៉ាខែ ។

ឈុនលី ៖ (ខ្យល់) ...?

ញឹម ៖ អត់ទេ........ ។

ឈុនលី ៖ គ្រប់គ្រាន់ដែរ?

ញឹម ៖ ........ ។

ឈុនលី ៖ ចឹងដល់ពេលឈប់ច្បាំងមែនទែន ពេលណា?

ញឹម ៖ ឈប់ច្បាំងផ្ដាច់ខ្លួន ៩៦ រកស៊ីរៀងខ្លួន ។

ឈុនលី ៖ ដល់ពេលផ្ដាច់ខ្លួនទៅ យើងឈប់ទទួលរបបហើយ?

ញឹម ៖ ឈប់ហើយ របបបានតែគេទាហាន ឈប់ចេះអត់បាន ។

ឈុនលី ៖ ពូឈប់តាំងពីអន្លង់?

ញឹម ៖ ឈប់ ផ្ដាច់ខ្លួនរួចឈប់បណ្ដោយ ។

ឈុនលី ៖ ហេតុអីបានពូឈប់?

ញឹម ៖ ខ្ជិល វាគ្មានប្រយោជន៍អី រកស៊ីៗធ្វើស៊ី ។

ឈុនលី ៖ ធ្វើអីគេពេលផ្ដាច់ខ្លួនភ្លាមៗ?

ញឹម ៖ ធ្វើចំការ ។

ឈុនលី ៖ ចឹងចំការនៅណាវិញ?

ញឹម ៖ ចំការខ្ញុំនៅ.... ។

ឈុនលី ៖ ចឹងពូទៅចាប់ដីនៅចំការហ្នឹងពេលណា?

ញឹម ៖ ផ្ដាច់ខ្លួនរួច ។

ឈុនលី ៖ អានឹងពេលនឹងចាប់ដីទៀត?

ញឹម ៖ ចាប់ ។

ឈុនលី ៖ គេអត់មានចែងទេ?

ញឹម ៖ អត់ទេ ចែកតែដីជិតនឹង ។

ឈុនលី ៖ ចឹងដោះមីន?

ញឹម ៖ ដោះ.... ។

ឈុនលី ៖ បានធំទេ ដីចំការ?

ញឹម ៖ ដីលក់អស់ហើយ ដីខ្ញុំបាន៣០រ៉ៃ ។

ឈុនលី ៖ នៅណា?

ញឹម ៖ ភ្នំរូង ជិតចំការ..... ហើយវាអត់ពេកទៅឈឺ ។

ឈុនលី ៖ ភ្នំរូង ភ្នំរាំង?

ញឹម ៖ ហ្នឹង ភ្នំរូង ភ្នំរាំង ។

ឈុនលី ៖ ហើយចឹងក្រោយមកទៀត ធ្វើស្រែចំការធម្មតា?

ញឹម ៖ ធម្មតាអត់ឈប់........ជួយតែប៉ុននឹង ។

ឈុនលី ៖ ចុះបើតាមការគិតរបស់ពូ ពេលដែលយើងធ្វើស្រែចំការខ្លួនឯងចឹងហូបគ្រប់គ្រាន់?

ញឹម ៖ គ្រប់ខ្លះ អឺ!មិនថាម៉េចម៉ាគ្រប់ៗ ។

ឈុនលី ៖ បើប្រៀបធៀបទៅ ពេលដែលយើងធ្វើទ័ព យើងមានរបបមានអីចឹង ដូចថាមួយណាវាប្រសើរជាង ពេលដែលយើងផ្តាច់ខ្លួនហើយ?

ញឹម ៖ ផ្តាច់ខ្លួនហើយវាប្រសើរជាង ។

ឈុនលី ៖ ប្រសើរជាង ហេតុអីបានចឹង?

ញឹម ៖ បើយើងស្រួល ស្រុកយើងឯករាជ្យហើយ ។

ឈុនលី ៖ តែជីវភាពរស់នៅ?

ញឹម ៖ រស់នៅស្រួល យើងចង់ដើរហើរទៅណាក៏បានរកស៊ីអីក៏បាន ពីដើមយើងដើរបានគ្មានដើរបានចែកទីគ្នាដូចខ្លានិងដំរី ។

ឈុនលី ៖ ចឹងក្នុងពេលនឹងពូចង់គេចពីទាហានខ្មែរក្រហមដែរ?

ញឹម ៖ ចង់គេច គេផ្តាច់ខ្លួនរួចខ្ញុំឈប់.... ។

ឈុនលី ៖ ចឹងបានន័យថាតំបន់ដែលពូរស់នៅហ្នឹង សុទ្ធតែខ្មែរក្រហមសុទ្ធ?

ញឹម ៖ ខ្មែរក្រហមសុទ្ធទាំងអស់ អត់មានលាយអីទេ សុទ្ធ ដល់សព្វថ្ងៃ..... ។

ឈុនលី ៖ ចា៎! ចុះដូចក្នុងកំឡុងពេល?

ញឹម ៖ ខ្លះណាគេធ្វើទាហានខាងសម្តេចផងទៅគេឈប់ទៅ ជួនទៅវារកស៊ីទៅវិញទៅមក ។

ឈុនលី ៖ .......?

ញឹម ៖ .........ឈប់ ។

ឈុនលី ៖ តាមពិតយើងត្រូវរួគ្នាចឹង គេឲ្យយើងធ្វើទ័ពធម្មតា?

ញឹម  :  ហ្នឹងគេអ្នកណាធ្វើគេធ្វើ  គេចូលទាំងអស់គ្នា  យើងរដ្ឋាភិបាលតែមួយទាំងអស់....ឈប់យើង វាចាស់ហើយ  ឈឺ ។

ឈុនលី  :  កាលនឹងពូអាយុប៉ុន្មាន  ពេលមកនឹង?

ញឹម  :  វាអាយុ..... ។

ឈុនលី  :  កាលហ្នឹងពូមានកូនប៉ុន្មាននាក់ដែរ?

ញឹម  :  ខ្ញុំអត់ទាន់មាន  ទើបបានកូនប្រុសមួយ ។

ឈុនលី  :  ចុះពូថាពេល៩៣មានកូនហើយ?

ញឹម  :  មានកូនៗ៩៣ហ្នឹង ។

ឈុនលី  :  ចុះសព្វថ្ងៃពូមានកូនប៉ុន្មាននាក់?

ញឹម  :  អត់ទេ  អស់ហើយ ។

ឈុនលី  :  មានតែមួយហ្នឹង?

ញឹម  :  មានតែមួយៗកូនប្រសារ  មួយចៅ ។

ឈុនលី  :  មួយណាកូនប្រសារ?

ញឹម  :  នោះ  ក្មេងនោះ ។

ឈុនលី  :  អ្នកស្រុកហ្នឹងដែរ  ដូចពូធ្លាប់ឆ្លងកាត់សង្គ្រាមមកអីចឹង  បើប្រៀបធៀបទៅសម័យឥឡូវ?

ញឹម  :  វាខុសគ្នា  ដូចថាខុសគ្នាដូចមេឃហើយនឹងដី ។

ឈុនលី  :  ម៉េចខ្លះពូ  អាពិបាក?

ញឹម  :  ចុះយើងមានអន្តរាយបានណា  បើយើងប្រយុទ្ធគ្នាគ្រាប់ផ្លោងមក  មានអន្តរាយបានណា  យើងចង់ដើរទៅណាក៏ដើរមិនបាន  បញ្ជារមេគេថាឲ្យនៅត្រង់ណា  យើងនៅត្រង់ហ្នឹង ។  ដល់យើងស្រុកយើងចេះទៅ  យើងចង់ដើរទៅត្រង់ណាក៏បាន  ចង់ដេកៗចង់ពួនៗ  ចង់ទៅរកៗ ។

ឈុនលី  :  ចុះពូដល់ពេលផ្តាច់ខ្លួនហើយ  ឬមួយក៏ពេលដែលពូមកនៅនេះឆ្នាំ៩៣ហើយចឹង  មានបងប្អូនមកតាមរកអត់?

ញឹម  :  មាន  ក្មួយៗមកតាមរក ។

ឈុនលី  :  គេមកដល់ហ្នឹងម៉ង?

ញឹម  :  គេមកដល់ហ្នឹង ។

ឈុនលី  :  អត់ទាន់ផ្តាច់ខ្លួនហ៊ានមកដែរ?

ញឹម  :  មកបានតើ  មកតាមផ្លូវយាយអតយើង ។

ឈុនលី  :  អត់ទាន់ផ្តាច់ខ្លួនមកបាន?

ញឹម ៖ មកបាន ។

ឈុនលី ៖ ចុះគេអត់ចាប់ទេ?

ញឹម ៖ អត់ទេ ។

ឈុនលី ៖ ម៉េចចឹង?

ញឹម ៖ ចុះបើខាងបងប្អូនមាននៅនោះ ។

ឈុនលី ៖ ខាងខ្មែរក្រហមក៏គេអត់គឹងតែង?

ញឹម ៖ អត់ចាប់ អត់គឹងទេ ធម្មតា ។

ឈុនលី ៖ ចុះពូឪពុកម្ដាយអី?

ញឹម ៖ ឪពុកម្ដាយមកនេះបាន ។

ឈុនលី ៖ ខួងឆ្នាំណាដែលគាត់មកលេង...?

ញឹម ៖ អ៊ុនគាត់វាចូលមកហ្នឹង......... ។

ឈុនលី ៖ ចុះមុនពេលគាត់មកលេងហ្នឹង គាត់ដឹងថាពូនៅតំបន់ហ្នឹងយូរហើយ?

ញឹម ៖ ដឹង ។

ឈុនលី ៖ ដឹងពេលណា?

ញឹម ៖ ដឹងខែដឹងថ្ងៃទេ យើងគ្រាន់តែផ្ញើសំបុត្រទៅ ។

ឈុនលី ៖ ពូផ្ញើសំបុត្រទៅឆ្នាំណា ពេលណា?

ញឹម ៖ ចាំអានោះមិនបាន ចាំមិនបាន តែមុនផ្ដាច់ខ្លួន ។

ឈុនលី ៖ តែដឹងថាមកនៅហ្នឹងហើយ បានផ្ញើសំបុត្រទៅ?

ញឹម ៖ បាទ! បានដឹង យើងនៅហ្នឹងហើយបានផ្ញើទៅ បងប្អូនមក ។

ឈុនលី ៖ ហើយពូទៅលេងស្រុកកំណើតអត់?

ញឹម ៖ ទៅតើ ។

ឈុនលី ៖ ទៅញឹកហ៎ពូ?

ញឹម ៖ ទៅមកៗ កូនទើបមកម្សិលមិញ កូនទៅ ។

ឈុនលី ៖ .......?

ញឹម ៖ .........ហ្នឹងហើយទៅមកៗ ។

ឈុនលី ៖ ចុះពូទៅលេងដំបូងពេលណា ផ្ដាច់ខ្លួននៅ?

ញឹម ៖ ផ្ដាច់ខ្លួនហើយ ផ្ដាច់ខ្លួនបានម៉ាខែទៅ ។

ឈុនលី ៖ ហើយទៅដល់ម៉េច?

ញឹម ៖ មានអីធម្មតា ។

ឈុនលី ៖ ទៅដល់ស្រុកភូមិយើង?

ញឹម ៖ ដល់ស្រុកភូមិចាស់ៗអស់ ម៉ាស្រុករៗគ្នាចាស់អស់ ។

ឈុនលី ៖ តែគាត់ដូចថាគាត់រាក់ទាក់ជាមួយយើង អ្នកជិតអ្នកខាង?

ញឹម ៖ អ្នកជិតអ្នកខាងរាក់ទាក់ ។

ឈុនលី ៖ ចុះគេមានដែលនិយាយថាពូខ្មែរក្រហមអីចឹង?

ញឹម ៖ និយាយដែរ ពួកអាពតវាចេះចុះ ។

ឈុនលី ៖ ហើយចឹងពូមានអារម្មណ៍ម៉េច បើគេហៅចឹង?

ញឹម ៖ ទេ! មានម៉េចយើងខុសដែរ យើងទឹងអីគេ ។

ឈុនលី ៖ ពូគិតថាខ្លួនឯងខុស?

ញឹម ៖ ហ្នឹង ។

ឈុនលី ៖ ហេតុអីបានពូគិតខ្លួនឯងខុស?

ញឹម ៖ មិនខុសម៉េច បើយើងនៅគ្រប់គ្រងរបស់គេ គេកេណ្ឌមកជាប់ ហើយយើងនៅក្រោម អាណានិគមន៍របស់គេ គេថាដេរអាពតៗបណ្ដោយ យើងអាពតមែន ។

ឈុនលី ៖ តែពូអត់មានថាអីឲ្យគេ?

ញឹម ៖ អត់ទេ មានថាអីឲ្យ……ចុះម៉ាស្រុករខ្ញុំគេសារភាព មុនគេទៅច្រើន ។

ឈុនលី ៖ សារភាពម៉េច?

ញឹម ៖ គេសារភាពគេចុះចូលជាមួយសម្ដេច?

ឈុនលី ៖ អូ! ដូចអ្នកមុនផ្ដាច់ហ្នឹង គេគេចខ្លួនទៅហ្នឹង?

ញឹម ៖ គេចូល ។

ឈុនលី ៖ ភាគច្រើនគេទៅពេលណា?

ញឹម ៖ ទៅម៉ាសារយើងច្របូកច្របល់ខ្លាំង ។

ឈុនលី ៖ ឆ្នាំណាអាហ្នឹងពូ?

ញឹម ៖ ឆ្នាំណា ពេលវៀតណាមដក ។

ឈុនលី ៖ ពូអាចរកនឹកបានទេ?

ញឹម ៖ រកនឹកអត់បាន ។

ឈុនលី ៖ ពូមកនៅនេះ?

ញឹម ៖ មុន និយាយរួមសម័យអ៊ុនគាត់ហ្នឹង ដែលចូលមកច្រើន ។

ឈុនលី ៖ ៧៣ហ្នឹង ចឹងពេលហ្នឹងលួចផ្តាច់ខ្លួនបណ្តោយៗ?

ញឹម ៖ ចូល ។

ឈុនលី ៖ ហើយចឹងមេខាងនេះគេអត់រករឿង?

ញឹម ៖ គេមានរករឿងអី គេថាយើងអត់មានប្រពន្ធមានកូន យើងដើរលេងៗទៅដល់យាយអ៊ីតទៅ ចេះទៅ ទៅបណ្តោយ ។

ឈុនលី ៖ ហើយខាងនោះអត់ចាប់យើងដែរ?

ញឹម ៖ អត់ចាប់ ។

ឈុនលី ៖ ដល់ពេលចឹងគេឲ្យដំណឹង?

ញឹម ៖ យើងទៅដល់កន្លែងឃុំ កន្លែងស្រុក យើងឲ្យគេនាំចូលទៅយើងសារភាពទៅចប់ ។ យើងធ្វើ ទាហានបម្រើរដ្ឋាភិបាលធ្វើទៅ ។ ពួកគ្នាខ្ញុំ...បងប្អូន..... ។

ឈុនលី ៖ ចឹងអ្នកទៅមុនហ្នឹងនៅក្នុងកងជាមួយគ្នា ទៅស្រុកកំណើតជាមួយគ្នា?

ញឹម ៖ នៅក្នុងកងគ្នា ហ្នឹងស្រុកកំណើតជាមួយគ្នា ។

ឈុនលី ៖ ហើយទៅគេប្រាប់អីចឹងទៅ?

ញឹម ៖ គេប្រាប់ចេះចុះ នៅរស់ត្រង់នេះត្រង់នោះ ។

ឈុនលី ៖ ហើយដល់ចឹងទៅអត់មានបញ្ហា?

ញឹម ៖ ទៅ ។

ឈុនលី ៖ ចុះបើពួកគាត់ទៅដំបូងអត់មានអី?

ញឹម ៖ អត់ទេ ទៅ....គ្នាឯងមករៀនសាលាស្រុករគ្នា....មេភូមិមេឃុំគេ..... ។

ឈុនលី ៖ ចឹងពេលគេនិយាយរឿងខ្មែរក្រហម ពូអត់ខឹងគេទេ?

ញឹម ៖ មានខឹងណា បើមេឃុំកាលពីជំនាន់ខ្ញុំមកគេកេណ្ឌមក គេមេឃុំក៏គេកេណ្ឌមក ។ ដល់ខ្ញុំសម័យ ផ្តាច់ខ្លួនដែលគេទៅវិញ មេឃុំជាប់ឈ្មោះដដែល មានថាឲ្យខ្ញុំមានសុំទោសខ្ញុំ ។

ឈុនលី ៖ មេឃុំនៅណា?

ញឹម ៖ មេឃុំនៅដានរុន ឃុំដាំ មេឃុំ... ។

ឈុនលី ៖ នៅខាងសៀមរាបហ្នឹង?

ញឹម ៖ នៅខាងសៀមរាប ។

ឈុនលី ៖ ម៉េចបានសុំទោស?

ញឹម ៖ សុំទោស បើកែណ្ឌសខ្ញុំឲ្យធ្វើខ្មែរក្រហម ។

ឈុនលី ៖ អ៊ឺ! សុំទោសវិញ?

ញឹម ៖ សុំទោស ។

ឈុនលី ៖ ហើយចឹងពូមានអារម្មណ៍ម៉េចទៅ?

ញឹម ៖ មិនដឹងធ្វើម៉េចបើសង្គមហ្នឹងវាធ្វើចឹងទៅហើយ ។

ឈុនលី ៖ ពូខឹងគាត់អត់?

ញឹម ៖ ខឹង ។

ឈុនលី ៖ ពីដើមដំបូងមក?

ញឹម ៖ .............សុំទោសអាប្អូនអញកេណ្ឌ...ឯងយ៉ាប់ ។

ឈុនលី ៖ ចុះពួកគាត់ហេតុអីបានរួចខ្លួន?

ញឹម ៖ ចុះពួកគាត់នៅតាមសហករណ៍ៗ នៅធ្វើមេសហករណ៍ ។

ឈុនលី ៖ ចឹងគាត់ធ្វើមេសហករណ៍ទៀត?

ញឹម ៖ អឺ!

ឈុនលី ៖ មេសហករណ៍នៅណា?

ញឹម ៖ មេសហករណ៍នៅស្រុក ។

ឈុនលី ៖ ដល់ពេលវៀតណាមចូលស្រុកគេបង្កើតភូមិ ឃុំវិញដដែល ។

ញឹម ៖ ហើយគាត់នៅធ្វើមេភូមិឃុំដដែល ។

ឈុនលី ៖ ហើយគាត់នៅធ្វើមេភូមិមេឃុំ?

ញឹម ៖ នៅដដែល ជាប់សព្វថ្ងៃ ។

ឈុនលី ៖ អ្នកណាអ្នកសុំទោស មេភូមិ ឬមេឃុំ?

ញឹម ៖ មេឃុំ ឈ្មោះ ដាំ ។

ឈុនលី ៖ គាត់ឈ្មោះដាំ?

ញឹម ៖ ហ្នឹងហើយ មេឃុំដាំ ដានរុន ។

ឈុនលី ៖ ឈ្មោះគាត់ឈ្មោះអីគេ មេឃុំ?

ញឹម ៖ មេឃុំ នាមត្រកូលហ្នឹងឯង ប៉ុនគេហៅមេឃុំដាំ ។

ឈុនលី ៖ ឃុំហ្នឹងគេហៅឃុំដាំ?

ញឹម ៖ មេឃុំ ដាំ ប៉ុនឃុំដានរុនបោះឆ្នោតជាប់ដល់សព្វថ្ងៃ.......ជាប់រហូតមក ។

ឈុនលី ៖ ចឹងគាត់គ្រប់គ្រងតាំងពីមុនសម័យខ្មែរក្រហមរហូតមកដល់ឥឡូវនេះ?

ញឹម ៖ បាទ! រហូតមកដល់ឥឡូវនេះ ធ្វើការល្អប្រជាជនស្រឡាញ់ ។

ឃុនលី ៖ ចុះបើតាមពូគិតអីចឹង ដូចថាពេលក្រោយផ្ដាច់ខ្លួនអីចឹង មានអ្នកថ្មីចូលៗមកចឹង ដូចថាពូចង់រាប់អានជាមួយគេទេ?

ញឹម ៖ រាប់អានគ្នា ស្គាល់គ្នា ចូលមកបងប្អូនគ្នា សាច់ឈាម ខ្មែរយើងទាំងអស់ មានអ្នកណាឈប់ប្រកាន់ពូជសាសន៍ហើយហ្នឹង ។

ឃុនលី ៖ ពូដូចយើងរស់នៅនេះយូរហើយអីចឹង ពេលដែលទៅលេងស្រុកកំណើតក្លាមៗពូចង់នៅហ្នឹងទេ?

ញឹម ៖ អត់ទេ ។

ឃុនលី ៖ ហេតុអីបានអត់ចង់នៅ?

ញឹម ៖ វាអត់មានការងារធ្វើ អត់មានស្រែចំការ បើស្រែចំការគេដកវាស់ចែកគ្នាអស់ហើយ តាំងកេរ្តិ៍អាករពីម៉ែពីឪមកអស់រលីង ។

ឃុនលី ៖ ៩០ប៉ុន្មានពូ សមាហរណកម្មហើយ?

ញឹម ៖ សមាហរណកម្មហើយ ។

ឃុនលី ៖ ៩៧ ៩៨?

ញឹម ៖ គេដកវាស់ចែកគ្នាអស់ខ្ទិល ...នៅស្រុកបាត់បើស្រែចំការខ្ញុំនៅ បើកុំចែកគ្នា នៅស្រុកបាត់ដល់ពេលស្រែចំការគេដកចែកគ្នា ។

ឃុនលី ៖ ចុះពូដូចពេលទៅលេងស្រុកអីចឹង ដូចពេលជួបបងប្អូនយើងកក់ក្ដៅទេ?

ញឹម ៖ ហ្នឹងហើយតែប៉ុនហ្នឹងឯង ។

ឃុនលី ៖ តែបើគិតពីអារម្មណ៍វិញ ថាពេលយើងទៅដល់ហ្នឹង យើងជួបបងប្អូនយើងអីចឹង យើងនៅតែគិតដល់កន្លែងនេះដដែល?

ញឹម ៖ នឹកផ្ទះយើងៗមានដែរ បើអត់ផ្ទះអត់អីទេ នឹកផ្ទះយើង ដល់ម៉ោង...នឹកផ្ទះសម្បែងយើងកេរ្តិ៍អាកររបស់យើងខំបានមក ។

ឃុនលី ៖ ចឹងបើគិតទៅវាបងប្អូនមែន តែយើងនៅឆ្ងាយអីចឹង បើយើងប្រៀបធៀបអ្នកជិតខាងនៅនេះពូគិតថា ពូថាដូចថាស្និតស្នាលឬមួយក៏ការនឹកគិតដល់អ្នកណាជាងគេ?

ញឹម ៖ នឹកគិតគ្រួសារខ្លួនឯង ។

ឃុនលី ៖ ដូចអ្នកជិតខាងអីម៉េចដែរ?

ញឹម ៖ អ្នកជិតខាងអីរាប់គ្នាជាបងជាប្អូន មកយើងស្រុកកំណើតយើងពីដើមមិញមាននៅនេះណាអ្នកស្រុកនេះអ្នកស្រុកនោះនៅជិតគ្នាក៏ដូចស្រុកកំណើតយើង រាប់អានគ្នាទៅ ឈឺថ្កាត់អីទៅមើលគ្នាចឹង ។

ឈុនលី ៖ ចុះពូដូចពេលដែលពូអត់ទាន់ផ្តាច់ខ្លួនអីចឹង ដូចថាការរាប់អានជាមួយអ្នកស្រុកជិតខាងអីយ៉ាងម៉េចដែរ?

ញឹម ៖ ដូចតែគ្នា ដូចសព្វថ្ងៃហ្នឹង......... ។

ឈុនលី ៖ ចុះដល់ពេលផ្តាច់ខ្លួនហើយរកស៊ីរៀងខ្លួន?

ញឹម ៖ រកស៊ីរៀងខ្លួនដូចគ្នា ។

ឈុនលី ៖ ប៉ុន្តែបើគិតទៅទំនាក់ទំនងពេលដែលមុនផ្តាច់ខ្លួន ហើយក្រោយផ្តាច់ខ្លួន មួយណាវាដូចថាជិតស្និតជាង ងាយស្រួលទំនាក់ទំនង......?

ញឹម ៖ ផ្តាច់ខ្លួនរួច ។

ឈុនលី ៖ ហេតុអីបានងាយស្រួលជាង?

ញឹម ៖ ងាយស្រួលជាង ។

ឈុនលី ៖ ហេតុអីបានចឹង?

ញឹម ៖ យើងនៅប្តីប្រពន្ធនៅជុំគ្នា ឈឺថ្កាត់អីទៅយើងរត់ទៅមើលគ្នាទៅ ។

ឈុនលី ៖ តែបើជាមួយអ្នកផ្សេងៗដូចអ្នកជិតហ្នឹង?

ញឹម ៖ ដូចតែគ្នាហ្នឹងឯង ថាឈឺរត់មើលគ្នា យកទៅមន្ទីរពេទ្យយកទៅអីទៅ ។

ឈុនលី ៖ ចុះនៅសម័យហ្នឹងយើងជួយគ្នាដែរតើ?

ញឹម ៖ ជួយគ្នាដែរ បើប្រុសនៅយើងចេះតែជួយ បើនៅតែស្រីៗទទេរប្រុសៗគេទៅអស់ហើយ វារកេរកាក់វាយ៉ាប់ មានការលំបាក ប្រុសៗវាលឿនជាងស្រីៗ..........វាទាន់ចិត្ត ហើយមីងៗម៉េចងាយ បើចៅជង កូនជងម៉េចងាយទាន់ចិត្ត ។

ឈុនលី ៖ ចឹងពូសម័យហ្នឹងធ្វើទ័ពរហូត ៣ឆ្នាំហ្នឹង?

ញឹម ៖ ខ្ញុំធ្វើរហូត ធ្វើតាំងពីអាយុ១៦ឆ្នាំ ។

ឈុនលី ៖ កាលនឹង១៦ឆ្នាំ?

ញឹម ៖ ១៦ឆ្នាំ ។

ឈុនលី ៖ ឆ្នាំ៧៣ហ្នឹង?

ញឹម ៖ បាទ! ១៦ឆ្នាំ ដំបូងទៅរកផ្ទះរកអត់ឃើញ មិនដឹងទៅរកណា ។

ឈុនលី ៖ ពេលទៅដំបូងហ្នឹង?

ញឹម ៖ ទៅដំបូង សួរគេ ។

ឈុនលី ៖ ហើយធ្វើម៉េច?

ញឹម ៖ សួរគេ ទៅពីនេះទៅដល់ដំដែកទៅសួរគេទៅ ។

ឈុនលី ៖ ចុះមីងអ្នកស្រុកនៅសៀមរាបនេះដែរ នៅជិតនេះ?

ញឹម ៖ ម៉ែវានៅនេះដែរ នៅខាងនេះ នៅសៀមរាបខាងលិច ។

ឈុនលី ៖ ចឹងអត់ស្គាល់គ្នាទេ?

ញឹម ៖ អត់ស្គាល់គ្នាទេ ។

ឈុនលី ៖ ទើបស្គាល់គ្នានៅពេលណា?

ញឹម ៖ ពេលដែលកេណ្ឌចូលទៅដីយួន វៀតណាមចូលស្រុក កាលនឹងមានកងអង្គភាពគេដឹកទៅឃោសនា ។

ឈុនលី ៖ ចុះពូដឹងថាមូលហេតុអីបានធ្វើឲ្យមានការផ្តាច់ខ្លួនហ្នឹងឡើង?

ញឹម ៖ ទេ! អានឹងមេគិតឃើញថា យើងនៅតស៊ូទៅយើងខ្មែរនិងខ្មែរដូចគ្នា ។

ឈុនលី ៖ អ្នកណាអ្នកនាំគំនិតដូចថាដឹកនាំឲ្យផ្តាច់ខ្លួនអីចឹង?

ញឹម ៖ មានណាមានអៀង សារី ។

ឈុនលី ៖ អូ! គាត់គ្រប់គ្រងនៅណា គ្រប់គ្រងតំបន់នៅណា?

ញឹម ៖ គ្រប់គ្រងម៉ាឡៃ ប៉ៃលិន តាម៉ុកអត់ដឹង គាត់អត់ផ្តាច់ គាត់អត់ចូលចិត្ត ។

ឈុនលី ៖ តាម៉ុកអត់ផ្តាច់?

ញឹម ៖ អត់ផ្តាច់ ម៉ាឡៃផ្តាច់មុនគេ ម៉ាឡៃ-ប៉ៃលិនផ្តាច់មុនគេ ។

ឈុនលី ៖ ចុះខាងផ្សេងទៀត ផ្តាច់ពេលណា?

ញឹម ៖ អន្លង់វែង?

ឈុនលី ៖ ចា៎!

ញឹម ៖ អន្លង់វែងក្រោយ មិនដឹងឆ្នាំប៉ុន្មាន យើងខាងនេះផ្តាច់កន្លះឆ្នាំ ជិតម៉ាឆ្នាំបានខាងនោះផ្តាច់ក្រោយ ។

ឈុនលី ៖ អាចខ្ទង់៩៧?

ញឹម ៖ ហ្នឹងជិតម៉ាឆ្នាំ នេះផ្តាច់មុន ។

ឈុនលី ៖ ពូដឹងថាមូលហេតុអីបានតាម៉ុកអត់ចង់ផ្តាច់ខ្លួន?

ញឹម ៖ តាម៉ុកគាត់យោធាផ្តាច់ការ ។

ឈុនលី ៖ ប៉ុន្តែចុះមូលហេតុអីបានធ្វើឲ្យគាត់អត់ផ្តាច់ខ្លួនបាន?

ញឹម ៖ ...ព្រោះថាអន្លង់វែង ម៉ាឡៃ ប៉ៃលិននេះស្គាល់គាត់ទាំងអស់ បើខាងនេះស្រួលហើយ យើងសុខចិត្តយ៉ាប់នោះទៅណាទៅទាំងអស់គ្នា ។

ឈុនលី ៖ ចឹងបើគិតទៅបើសិនជាពូអត់ត្រូវបានគេដោះដូរមកខាងនេះវិញ ពូផ្តាច់ក្រោយគេ?

ញឹម ៖ ផ្តាច់ក្រោយគេ........ ។

ឈុនលី ៖ ពូដឹងទេថាអន្លង់វែងតាអៀង សារី គាត់គ្រប់គ្រងតំបន់....ពីឆ្នាំណាដល់ឆ្នាំណា?

ញឹម ៖ អៀង សារី និយាយរួមក្តាប់ពី៧៩មក ។

ឈុនលី ៖ តាមពី៧៩មក?

ញឹម ៖ រហូតដល់ពេលផ្តាច់ខ្លួន ផ្តាច់គាត់អ្នកនាំផ្តាច់មុនគេ ។

ឈុនលី ៖ ហើយអ្នកនាំមកក៏គាត់?

ញឹម ៖ គាត់ ។

ឈុនលី ៖ ចឹងពីដំបូងមកគេហៅតំបន់អីគេ តំបន់ទីប៉ុន្មាន ពីព្រោះខ្ញុំមានចែកតំបន់១ តំបន់២អីចឹង?

ញឹម ៖ បើគិតទៅតំបន់៥ ដីនេះតំបន់៥ពីដើមមិញ ដីនេះតំបន់៥ ។

ឈុនលី ៖ តំបន់៥ មិនមែនតំបន់៣ទេ?

ញឹម ៖ ទេ! តំបន់៥ ។

ឈុនលី ៖ ចុះតំបន់៣?

ញឹម ៖ អឺ! តំបន់៣ៗ តំបន់៥ នៅខាងនោះ..... ។

ឈុនលី ៖ ចឹងតំបន់៣?

ញឹម ៖ តំបន់៣ ។

ឈុនលី ៖ ហើយអាទីងគេហៅភូមិភាគអីគេ?

ញឹម ៖ ពាយ័ព្យ ។

ឈុនលី ៖ ពូដែលឃើញមុខតាអៀង សារីអត់?

ញឹម ៖ ឃើញតើ ។

ឈុនលី ៖ ឃើញពេលណា?

ញឹម ៖ ឃើញពេលដែលគាត់មកសារតាំង ។

ឈុនលី ៖ មកសារតាំង?

ញឹម ៖ ហ្នឹង.... ។

ឈុនលី ៖ អាហ្នឹងពេលណាបានពូបានឃើញចឹង?

ញឹម ៖ កាលពីសម័យសង្គ្រាម ។

ឈុនលី ៖ ខ្ទង់ពេលណា?

ញឹម ៖ ប៉ុន្មានអត់ចាំទេ ខែថ្ងៃ ពេលគាត់មកគេហៅទៅទទួល.... ។

ឈុនលី ៖ សារតាំងហ្នឹងគេធ្វើដើម្បីអី?

ញឹម ៖ សារគាំងនេះ ពីដើមមិញល្ងាចមិនដឹងដែរ ប៉ុន្តែចាស់ៗគេនិយាយថា កន្លែងសម្តេចពីដើម ។

ឈុនលី ៖ សម្តេចឪហ្នឹង?

ញឹម ៖ កន្លែងហ្នឹង ។

ឈុនលី ៖ គាត់មកធ្វើអី?

ញឹម ៖ ទៅសម្ពោធន៍ មើលព្រំដែន មកសារគាំងៗរបូត ។

ឈុនលី ៖ បើតាមការគិតទៅ ដូចថាតំបន់នេះមកដល់ដំបូងសុទ្ធតែព្រៃចឹង បើយើងគិតទៅរយៈពេលប៉ុន្មានដែលអាចធ្វើឲ្យព្រៃហ្នឹងទៅជាវាល?

ញឹម ៖ ម៉ាឆ្នាំជាងៗ ។

ឈុនលី ៖ លឿនម៉េច?

ញឹម ៖ ហ៎! ចុះបើដីចាប់រករៀងៗខ្លួន ។

ឈុនលី ៖ ចុះក្រែងថាមកហ្នឹង បើសិនយើងរាប់ចាប់តាំងពីយើងចូលមកដល់ទឹកដីនេះ?

ញឹម ៖ ហ្នឹងហើយយើងកាប់យកតិចៗ ដោះមីនតិចៗ ។

ឈុនលី ៖ ប្រហែលប៉ុន្មានឆ្នាំ បើគិតទៅ?

ញឹម ៖ បើគិតទៅ៥-៦ឆ្នាំ វាលអស់ ។

ឈុនលី ៖ ចាប់ផ្តើមវាលមែនទែន ក្លាយជាភូមិចឹងពេលណា ឆ្នាំណា ផ្តាច់ខ្លួនហើយនៅ?

ញឹម ៖ ផ្តាច់ហើយ ។

ឈុនលី ៖ ចុះមុន?

ញឹម ៖ អាចថា២០០៣ ២០០៤ ត្រូវវាលអស់ ។

ឈុនលី ៖ ចុះពេលផ្តាច់ខ្លួនហ្នឹង អត់ទាន់វាលអស់?

ញឹម ៖ នៅ ព្រៃពើង ។

ឈុនលី ៖ នៅម្តុំណា?

ញឹម ៖ ព្រៃនៅតាមនេះ ។

ឈុនលី ៖ ម្តុំហ្នឹងមានព្រៃ?

ញឹម ៖ ព្រៃ ។

ឈុនលី ៖ ចុះមនុស្សច្រើនពេលណា?

ញឹម ៖ មនុស្សច្រើនវាពេលផ្តាច់ខ្លួនរួច យើងកន្លែងនេះផ្តាច់ខ្លួនរួច ចាប់ពីកន្លែង..........មកនេះផ្តាច់ខ្លួនរួចបានច្រើន មនុស្សសំរុកមកនៅទិញដីនៅមកនៅ ខ្លះគេនេះក៏ចាប់បានគេនៅមុនយើងចេះមកក្រោយយើងទិញបន្តៗគ្នាៗទៅណា ។

ឈុនលី ៖ ហើយមកដល់ភូមិណាមានព្រៃកាប់បន្ថែម?

ញឹម ៖ កាប់បន្តទៀតទៅ ខ្លះនោះគេចាប់ចំការ កាលនោះយើងមិនសម្តេចបើកដៃឲ្យយើងចាប់ដីចំការដីធ្លី សម្តេចកាលនោះសម្បោធន៍ ។

ឈុនលី ៖ ចឹងបើអ្នកណាចាប់បានតិចច្រើនអីឈ្លោះគ្នាដែរ?

ញឹម ៖ ទេ! មានឈ្លោះខ្លះ ។

ឈុនលី ៖ ចឹង?

ញឹម ៖ តែឈ្លោះទៅមេភូមិមេឃុំកែសម្រួលក៏ចប់គ្នាទៅ ។

ឈុនលី ៖ ចុះហេតុអីបានមេភូមិមេឃុំគេអត់ចាប់ឲ្យចឹង?

ញឹម ៖ អត់ទេ អត់មានចាប់ទេ កាលនោះរៀងខ្វះ ។

ឈុនលី ៖ ចុះមាន ចាប់ផ្តើមមានមេភូមិមេឃុំគ្រប់គ្រងតាំងពីពេលណាឆ្នាំណា?

ញឹម ៖ អឺ!តាំងពីខ្មែរក្រហមមករួច មេឃុំមេភូមិដូចគ្នា ។

ឈុនលី ៖ ចុះដូចមីងមេភូមិ?

ញឹម ៖ មីងៗមេភូមិវាលហាត់ ។

ឈុនលី ៖ មេភូមិ គាត់ធ្វើតាំងពីពេលណា?

ញឹម ៖ យាយនេះក្រោយទេ មេឃុំសុខក៏ក្រោយ មេឃុំចាស់គាត់ឈប់ហើយ គាត់ចាស់គាត់Retire

ឈុនលី ៖ បើគិតទៅឆ្នាំណាទៅ ដែលមានមេភូមិត្រឹមត្រូវ?

ញឹម ៖ មេភូមិត្រូវតាំងពីណាទេ ។

ឈុនលី ៖ ផ្តាច់ខ្លួននៅ?

ញឹម ៖ នៅ មេភូមិចាស់ ។

ឈុនលី ៖ អត់ទាន់ផ្តាច់ខ្លួនហ្នឹង មានមេភូមិហើយ?

ញឹម ៖ មានរបួត ។

ឈុនលី ៖ ចុះកាលពូមក៩៣ហ្នឹង មានអ្នកណាគេទៀត?

ញឹម ៖ ហ្នឹងតាវ៉ាន់....សព្វថ្ងៃគាត់ចាស់ហើយ ។

ឈុនលី ៖ តាវ៉ាន់ហ្នឹងគាត់ធ្វើដែរ ពីដើមមក?

ញឹម ៖ ខ្មែរក្រហមដូចតែគ្នា ។

ឈុនលី ៖ ទ័ព ឬមួយក៏មេច?

ញឹម ៖ ទ័ព បើនេះគាត់កំបុតដៃទៅ ចាប់ឆ្នោតៗធ្វើប្រធានភូមិ ។

ឈុនលី ៖ បន្ទាប់ជាមួយពូដែរ?

ញឹម : អត់ទេ! កំបុតតាំងពីភ្នំពេញមក មិនដឹងកំបុតតាំងពីអង្គាល់ណា យើងមកចឹងជួបគ្នាស្គាល់គ្នាទៅ ។

ឈុនលី : ប៉ុន្តែទ័ពគាត់ខាងណា?

ញឹម : ខាងខ្មែរក្រហម ។

ឈុនលី : នៅតំបន់ណា ដូចនៅខាងពូអត់ នៅខាងអន្លង់វែង?

ញឹម : អត់ទេគាត់កំបុតពីសម័យហ្នឹង ដឹងកំបុតនៅណានៅភ្នំពេញ វ៉ៃរំដោះភ្នំពេញយូរដែរ ។

ឈុនលី : គាត់អ្នកស្រុកណា មេភូមិ?

ញឹម : អត់ស្គាល់ទេ គាត់នៅចំការ ។

ឈុនលី : ពូចុះអាពេលពូថាយើងនៅអន្លង់វែង ប៉ុន្តែយើងចេញចូលនេះ ចឹងវាខ្ទង់ឆ្នាំ៨០ជាងមែនអត់?

ញឹម : ៨០ជាង ។

ឈុនលី : ចឹងពេលហ្នឹងមានមេភូមិទៀត?

ញឹម : មានរហូតគ្រប់កន្លែង មេភូមិមេឃុំ ប៉ូលីសមានដូចគ្នា ប៉ុនកាលហ្នឹងគេមិនហៅប៉ូលីស គេហៅតម្រួត ។

ឈុនលី : ប៉ុន្តែអាហ្នឹងនៅមុំខាងរាប់ទេ?

ញឹម : ហ្នឹងខាងរាប់ៗ ប្រជាជនរបូតពីខាងរាប់មកចេះ ដល់ពេលសភាពការណ៍តឹងតែងប្រជាជនរត់មកនៅនេះទាហាន ។

ឈុនលី : តឹងតែងខ្លាំងឆ្នាំណា?

ញឹម : មុនដាច់ខ្លួន ។

ឈុនលី : ខ្ទង់៩៤ ៩៥?

ញឹម : ហ្នឹង តឹងម៉ាប្រាវ យើងថាប្រហែលម៉ាឆ្នាំអីទៅដាច់ខ្លួនបណ្តោយ ។

ឈុនលី : ចឹងបានន័យថា៩៥?

ញឹម : ហ្នឹង៩៥ ។

ឈុនលី : កាលហ្នឹងម៉េចខ្លាំង មានថាទ័ពមកច្រើន?

ញឹម : ទ័ពច្រើន ទ័ពពីនេះមកពីនោះទៅមក.... ។

ឈុនលី : ហើយស្បៀងអីយកមកពីខាងណាទៅ?

ញឹម : ដឹកចេញពីថៃ ។

ឈុនលី : អាវុធនោះ?

ញឹម ៖ អាវុធដឹកចេញពីថៃមកទាំងអស់ បើមុនផ្តាច់ខ្លួនម៉ាឆ្នាំហ្នឹងអត់មានទេ អត់មានគ្រាប់ទេ ។

ឈុនលី ៖ ម៉េចចឹង?

ញឹម ៖ អស់គ្រាប់ មានតែគ្រាប់មេៗ វាលាក់តាមមេៗ គេលាក់តាមឃ្លាំងចាស់ៗ កាលនៅចាស់ៗ អស់ ។

ឈុនលី ៖ ចុះអាពេលដែលថាឆ្នាំ៩៥ ដែលបាញ់គ្នាខ្លាំងហ្នឹង គ្រាប់ហ្នឹងយកមកពីណា ពេលដែលលាក់ហ្នឹង?

ញឹម ៖ ទិញៗពីក្នុង ។

ឈុនលី ៖ ទិញពីក្នុង?

ញឹម ៖ ទិញពីប៉ោយប៉ែត ចូលមកម៉ាឡៃ ។

ឈុនលី ៖ ប៉ោយប៉ែតយកមកពីណា?

ញឹម ៖ ប៉ោយប៉ែតលួចតាមទាហានៗ លក់ឲ្យ ។

ឈុនលី ៖ គិតទៅទាហានហ្នឹងលក់គ្រាប់មកឲ្យបាញ់គ្នាឯង?

ញឹម ៖ ហ្នឹងបាញ់តែប្តីឯង មករះម្តងចឹងទៅវៃគ្នាហើយទៅវិញ............ទិញមកប្រពន្ធអ្នកលក់ឲ្យ ។

ឈុនលី ៖ ដូចលក់ឲ្យហើយបាញ់គ្នាឯងម៉េច បាញ់ឯងម៉េច?

ញឹម ៖ លក់ឲ្យបាញ់ខ្លួន លុយធំ ។

ឈុនលី ៖ ពេលហ្នឹងពូឃើញស្ថានភាពចឹងម៉េចទៅ ដូចថាទិញគ្រាប់មកបាញ់គ្នាឯងអីចឹង ដូចពូគិតថាម៉េច ពេលហ្នឹង?

ញឹម ៖ ថាគ្មានអីស្លាប់តែខ្មែរគ្នាឯង ។

ឈុនលី ៖ ពេញចិត្តហ្នឹងធ្វើដែរ?

ញឹម ៖ បាទ! បើយើងមិនធ្វើ វាមិនកើត ។

ឈុនលី ៖ ចុះពូដែលមានគំនិតមួយចង់ផ្តាច់ខ្លួនមុនពេល?

ញឹម ៖ ខ្ញុំដឹងមុនហើយ ។

ឈុនលី ៖ ដឹងម៉េច?

ញឹម ៖ ខ្ញុំដឹងផ្តាច់ខ្លួនមុន ខ្វះណាខ្ញុំដែលហ៊ាននិយាយប្រាប់គេ ខ្លាចគេខ្ញុំខុស...... ។

ឈុនលី ៖ ម៉េច ហេតុអីបានពូដឹង?

ញឹម ៖ ដឹងពីបងខ្ញុំ ។

ឈុនលី ៖ បងពូធ្វើអី?

ញឹម ៖ បងខ្ញុំវរសេនាធំ ។

ឈុនលី ៖ វរសេនាធំនៅណា?

ញឹម ៖ នៅយើង សព្វថ្ងៃអធិការ ។

ឈុនលី ៖ គាត់ឈ្មោះអីគេ?

ញឹម ៖ ឈ្មោះ ប៊ុន ។

ឈុនលី ៖ ប៊ុន ត្រកូលអីគេ?

ញឹម ៖ ......... ។

ឈុនលី ៖ ចុះកាលពីដើមមកគាត់ធ្វើអីគេ?

ញឹម ៖ ខ្មែរក្រហមដូចគ្នា ។

ឈុនលី ៖ តែឋានៈគាត់?

ញឹម ៖ ឋានៈគាត់វរសេនាធំ ។

ឈុនលី ៖ វរសេនាធំប្រចាំតំបន់អីគេ?

ញឹម ៖ តំបន់ស៊ីសាផុនខាងត្បូង ខាងភ្នំឆ័ត្រស៊ីសាផុនខាងជើង....ដល់នេះទៅគាត់ចេះឡើងៗ ទៅខ្ញុំក៏នៅធ្វើប៉ូលីសជាមួយគាត់ឈ្មោះខ្ញុំ តែខ្ញុំអត់ធ្វើ ។

ឈុនលី ៖ សព្វថ្ងៃហ្នឹង?

ញឹម ៖ ខ្ញុំអត់ធ្វើ ។

ឈុនលី ៖ សព្វថ្ងៃហ្នឹង?

ញឹម ៖ បាទ! ខ្ញុំអត់ធ្វើ ធ្វើរាស្ត្រសាមញ្ញស្រួលជាងរកស៊ីៗ បានណាគេហៅ ។

ឈុនលី ៖ ចុះដល់ពេលដូចពូមានបងប្អូនអីចឹងហើយ ម៉េចក៏ពូនៅតែធ្វើទ័ពទៀត ហើយរត់អត់រួចអីចឹង?

ញឹម ៖ ខ្ញុំៗអត់ទេ ខ្ញុំវាមិនចង់ ។

ឈុនលី ៖ អាពេលក្នុងសម័យហ្នឹង ដូចថាយើងមានបងប្អូនធ្វើធំដែរ?

ញឹម ៖ យើងគេចអត់រួចទេ ។

ឈុនលី ៖ ចុះហេតុអីបានយើងឡើង គាត់ជួយយើងឲ្យឡើង?

ញឹម ៖ ជួយអត់បាន ។

ឈុនលី ៖ ហេតុអីបានជួយអត់បាន?

ញឹម ៖ បើជួយបាន តែខ្ញុំអត់ធ្វើ ។

ឈុនលី ៖ អាពេលសម័យហ្នឹង?

ញឹម ៖ ហ្នឹងហើយ ឲ្យខ្ញុំធ្វើវរៈធ្វើអី ខ្ញុំអត់ធ្វើ ។

ឈុនលី ៖ ហេតុអីបានពូមិនធ្វើចឹង?

ញឹម ៖ មិនចង់ ទៅណាឈ្មោះយើងជាប់ហើយ ពេលណាយើងចង់ឈប់អត់ងាយធ្វើបានទេ។

ឈុនលី ៖ ចុះបើធ្វើកូនទាហានធម្មតា?

ញឹម ៖ ធម្មតា កូនទាហានធម្មតា គ្រាន់ចង់ឈប់ៗ ផ្តាច់ខ្លួនវិញប្រាប់ថាអត់ធ្វើទេ កុំហៅ ខ្ញុំឈប់ហើយ យកកាំភ្លើងប្រគល់ឲ្យគេហ្នឹង។

ឈុនលី ៖ ពូដឹងហ្នឹងដឹងពេលណា ដឹងមុនពេលផ្តាច់ខ្លួន?

ញឹម ៖ មុនម៉ាឆ្នាំ កាលអ៊ុនតាក់ទៅផុត។

ឈុនលី ៖ ចឹងបានន័យថា?

ញឹម ៖ មេៗ បងៗដែលគាត់ទៅរៀន គាត់ប្រាប់ថាយើងផ្តាច់ខ្លួន ខ្ញុំមិនហ៊ាននិយាយ គ្រាន់ដឹងសួរថាប្រពន្ធកូនៗមិនហ៊ាននិយាយប្រាប់ទៀតខ្លាចគេថាចេះចុះ ដឹងក្នុងពោះឯង ចេះថា ហើយយើងនិយាយលេងគ្នាឯងទៅ យើងថាតិចទៀតស្រួលហើយ។

ឈុនលី ៖ ចុះពូខ្ញុំពូថា ដូចជាមុនពេលផ្តាច់ខ្លួនហ្នឹង ដូចគេចង់បង្កើតសហករណ៍នៅហ្នឹងទៀត?

ញឹម ៖ មុនផ្តាច់ខ្លួនហ្នឹង។

ឈុនលី ៖ ដូចថាប្រមូលទ្រព្យសម្បត្តិ?

ញឹម ៖ ប្រមូលៗមែន។

ឈុនលី ៖ អាហ្នឹងឆ្នាំណា?

ញឹម ៖ ឆ្នាំអ៊ុនតាក់នៅហ្នឹងឯង ប្រមូល។

ឈុនលី ៖ ៩៣?

ញឹម ៖ អឺ! ៩៣។

ឈុនលី ៖ បោះឆ្នោតនៅពេលហ្នឹង?

ញឹម ៖ អត់ទាន់បោះទេ។

ឈុនលី ៖ ខ្ទង់៩១ ៩២?

ញឹម ៖ ហ្នឹងមុនបោះឆ្នោត។

ឈុនលី ៖ ម៉េចខ្លះពូពេលហ្នឹង?

ញឹម ៖ គេចាំមើលបើយើងដឹកឈើចេះ គោគេកាប់ស៊ី រទេះដុតចោល ម្ចាស់ជាប់គុក។

ឈុនលី ៖ ម៉េចចឹង?

ញឹម ៖ អត់បាន ប្រមូលដាក់អស់។

ឈុនលី ៖ ខាងណាអ្នកបញ្ជាមកចឹង?

ញ៉ឹម ៖ ខ្មែរក្រហមបញ្ជា មេខ្មែរក្រហមបញ្ជាផ្ទាល់ ។

ឈុនលី ៖ ហ្នឹងហើយប៉ុន្តែមេខាងណា?

ញ៉ឹម ៖ មេតាមកងពល ថានេះរកចូលគ្នាមិនឃើញ ដល់ផ្តាច់ខ្លួនពុំនិយាយតាមជាន់ថ្នាក់បញ្ជាមកពីលើដែរ ។

ឈុនលី ៖ ប៉ុន្តែគ្រាន់ថាតំបន់នេះ ដូចថាលោកសុខ ភាពអីចឹង?

ញ៉ឹម ៖ បាទ! កាលណាគេឲ្យរកស៊ីខាំង អត់មានទាហានច្បាំង ចាប់ផ្តើមបណ្តឹង ដល់បណ្តឹងចឹងទៅយើងពង្រឹកដើម្បីការពារដី ។ ដល់មុនហ្នឹងរៀបផ្តាច់ខ្លួនមុនម៉ាខែ ក៏គេប្រកាសប្រាប់តាមកងពល តាមវរៈ ។ យើងខំ.......ការពារផ្តាច់ខ្លួនប្រឹប ៗ .........បានចែកដីគ្នាត្រឹមណា ៗ ..... ។

ឈុនលី ៖ តែចង់និយាយថាចេះដូចលោក សុខ ភាព គាត់អ្នកគ្រប់គ្រងតំបន់ហ្នឹង?

ញ៉ឹម ៖ លោក សុខ ភាព ។

ឈុនលី ៖ ចឹងបានន័យថាគាត់ជាអ្នកបញ្ជាឲ្យប្រមូលទ្រព្យសម្បត្តិឯកជនហ្នឹងវាយ៉ាងម៉េច?

ញ៉ឹម ៖ បាទ! យកទុក យកដាក់ ផ្តាច់ខ្លួនគេយកវិញអស់ហើយ ឡាន មានទាំងឡាន ។

ឈុនលី ៖ ប្រមូលអស់ហើយ ដាក់នៅណា?

ញ៉ឹម ៖ ដាក់ឃ្លាំង ៗ សាមគ្គីឯត្បូងនោះ ដល់ពេលផ្តាច់ខ្លួននេះយើងយកវិញ ។

ឈុនលី ៖ អាហ្នឹងពេលមកដំបូងយើងមានឡានដែរ?

ញ៉ឹម ៖ មាន អូ!សំបូរណាស់ឡានស្រុកនេះ ។

ឈុនលី ៖ ឆ្នាំ៩០ប៉ុន្មាន ៩២ ៩៣?

ញ៉ឹម ៖ ៩២ ៩៣ ។

ឈុនលី ៖ ពូមានដែរ?

ញ៉ឹម ៖ អត់ទេ ខ្ញុំគ្មានទេ.........ខ្មែរយើងគេមានៗ គេទិញឡានបើក ។

ឈុនលី ៖ បើសិនចង់ប្រមូលចឹង ចុះហេតុអីចង់ផ្តាច់ខ្លួនវិញ?

ញ៉ឹម ៖ ប្រមូលអស់នេះបានឈឺចាប់ចង់ផ្តាច់ខ្លួនហ្នឹង ។ ដល់ហើយរបស់ទ្រព្យរបស់របរយើងខំរក ។

ឈុនលី ៖ ប្រជាជនតវ៉ាដែរ?

ញ៉ឹម ៖ អត់មានអ្នកណាហ៊ានតវ៉ាទេ ។

ឈុនលី ៖ ចុះអ្នកណាគេអ្នក?

ញ៉ឹម ៖ ដល់ផ្តាច់ខ្លួនមេនាំផ្តាច់ ។

ឈុនលី ៖ ចុះមេហ្នឹងបញ្ជាឲ្យប្រមូលហើយ?

ញ៉ឹម ៖ មេនាំផ្តាច់ ។

ឈុនលី ៖ នាំផ្កាចវិញ?

ញឹម ៖ ហ្នឹងហើយ មេនាំផ្កាចវិញ អានេះឡាន........រទេះអីគោអីមានបានណា ម្ចាស់ខ្លួនយើង ។

ឈុនលី ៖ ប្រមូលទាំងរទេះទៀត?

ញឹម ៖ ....................ដល់ពេលនេះគេយកវិញ ឡានខ្លួនឯងយកវិញ ។

ឈុនលី ៖ គេចុះឈ្មោះចុះអីត្រឹមត្រូវ?

ញឹម ៖ សោនៅយើង គេចាក់ដល់ដាក់ផ្ទះយកសោរផ្ទះ ។

ឈុនលី ៖ ចឹងពេលហ្នឹងហេតុអីបានមានលុយចាយអីច្រើន ទិញឡាន ទិញម៉ូតូបាន?

ញឹម ៖ គេរកស៊ី ដួញដូរ ដួញគោ ដួយក្របី ដួយដូរច្រើនណាស់ ។

ឈុនលី ៖ មុនបោះឆ្នោតហ្នឹង?

ញឹម ៖ .........ទិញពីក្នុងនោះយកមកលក់ឲ្យថៃ ទិញបន្តគ្នាចំណេញតគ្នារបូត ។ គេមេៗគេរកបាន យើងកូនៗមានរក ឲ្យស៊ីៗ គេមិនឲ្យស៊ីអត់ប៉ុនហ្នឹង ។

ឈុនលី ៖ បើតាមពូគិតអីចឹង បើសិនជាដូចថាអ្នកដែលរស់នៅខាងក្នុងៗ គេអាចហ្នឹងខឹងសម្បារជាមួយខ្មែរក្រហម ។

ញឹម ៖ ខឹងហើយ ខឹងអី បើសព្វថ្ងៃបាត់ខឹងអស់ហើយ វាចូលទៅមិត្តភាព ។

ឈុនលី ៖ ពូគិតថាគេបាត់ខឹង?

ញឹម ៖ បាត់ហើយ បញ្ចូនទៅស្រុកវិញ គេមិនខឹង គេយល់ដឹងពីយើងកូនចៅយើងគ្រាន់នៅក្រោមអាណានិមគន៍របស់គេ ក្រោមបទបញ្ជារបស់គេ ឲ្យទៅណាទៅត្រង់នោះ ។

ឈុនលី ៖ ចុះបើសិនជាអ្នកនៅតែខឹង ឧទាហរណ៍ថាអ្នកជិតខាងរបស់ពូខឹងអីចឹង? ដូចថាអ្នកនៅស្រុកកំណើតរបស់ពូ គាត់ខឹងអីចឹង ថាពូហ្នឹងចូលជាមួយខ្មែរក្រហមអីចឹង ។ ហើយមានអ្នកចំណូលថ្មីដែរ ប៉ុន្តែគេរស់នៅជិតៗនេះ ដូចថាគេខឹងជាមួយយើងដែរ ។ ហើយបើសិនជាពេលហ្នឹង ពូចង់ត្រូវរូវជាមួយគេអត់ ចង់ឲ្យគេបាត់ខឹងជាមួយយើងអីចឹង?

ញឹម ៖ ទេ! សព្វថ្ងៃវាមិនព្រួ តាមដាក់ស្ដែងអត់មានទេ ។

ឈុនលី ៖ បើសិនជាឧទាហរណ៍ បើសិនជាមានពូវាម៉េចវិញ?

ញឹម ៖ អានេះយើងនិយាយជាមួយគេទៅ ចុះយើងមានទៅដឹងអី យើងនៅក្រោមអាណានិគមន៍របស់គេ ។

ឈុនលី ៖ ចុះបើសិនជារវាងអ្នកនៅឆ្ងាយ ហើយនឹងអ្នកនៅជិតនេះ ចឹងពូគិតថាមួយណាដែលយើងអាចធ្វើឲ្យគេបញ្ចុះបញ្ចូលគេឲ្យគេឈប់ខឹងយើងបានលឿនជាង?

ញ៉ឹម ៖ អាហ្នឹងយើងនិយាយតាម យើងនិយាយថាធ្វើម៉េចបើវានៅក្នុងសង្គមរបស់គេ ដូចលោកឯងចឹងនៅក្រោមសង្គមសម្តេច ខ្ញុំចេះនៅក្រោមអាណានិគមន៍របស់ខ្មែរក្រហមចេះ ហើយចឹងយើងផ្តាច់ខ្លួន យើងត្រូវរូវគ្នា មិនដែលមានពូអ្នកណានិយាយផង មកវិញ។ ដូចអត់មានអ្នកណាខឹង អត់មានខឹងទេ សព្វថ្ងៃអត់មាន បើនិយាយឲ្យខ្ញីអត់មាន។ មានតែត្រូវរូវគ្នារកស៊ីគគ្រឹក គេកម្មករយើងៗទៅកម្មករគេទៅមកៗចេះ។

ឈុនលី ៖ ចឹងដូចថាពូធ្លាប់ឆ្លងកាត់រស់នៅ ហើយធ្វើជាខ្មែរក្រហមផ្ទាល់អីចឹង ប៉ុន្តែបើប្រៀបធៀបមកពេលសម័យការដែលយើងរកស៊ីខ្លួនឯងអីចឹង យើងគិតថារបបនេះវាប្រសើរជាអីចឹង?

ញ៉ឹម ៖ ប្រសើរជាង អភិវឌ្ឍន៍បានច្រើន។

ឈុនលី ៖ ចុះទោះបីនៅក្នុងហ្នឹងយើងមានការហូបចុកច្រើនជាងរបបនេះអីចឹង?

ញ៉ឹម ៖ វាការហូបចុកវា យើងកាលនោះរបស់គេឲ្យ យើងចង់ទៅខ្លាចវាខុះខាត សម័យសព្វថ្ងៃយើងរកខ្លួនយើង................។

ឈុនលី ៖ ពូមានអីចង់សួរ ឬមួយចង់បន្ថែម?

ញ៉ឹម ៖ បានស្រួលកូនចៅរកស៊ីសប្បាយគ្រប់ៗគ្នាកុំឲ្យខុះខាត ហើយវាបានជឿនលឿន ដូចប្រទេសគេក្រៅៗទៀត។

ឈុនលី ៖ ចា៎! ចឹងអរគុណពូ។

«ចប់»